# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



# សៀវភៅណែនាំ
# ស្តីពី
# ផលិតកម្មគ្រាប់ពូជស្រូវ

រៀបចំដោយ:
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
សហការជាមួយ នាយកដ្ឋានដំណាំស្រូវ និងនាយកដ្ឋានការពារដំណាំ
អនាម័យ និងភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ព ដោយ:ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បោះពុម្ពឆ្នាំ២០២១

# សៀវភៅណែនាំ

## ស្តីពី

# ផលិតកម្មគ្រាប់ពូជស្រូវ

រៀបចំដោយ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
សហការជាមួយ
នាយកដ្ឋានដំណាំស្រូវ និងនាយកដ្ឋានការពារដំណាំ
អនាម័យ និងភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម

រក្សាសិទ្ធិដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សមាសភាពចូលរួមចំណែកផលិតសៀវភៅណែនាំ
# ស្តីពីផលិតកម្មគ្រាប់ពូជស្រូវ

## I. ទីប្រឹក្សាផ្តល់យោបល់:

១. បណ្ឌិត **ម៉ៅ មិនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២. បណ្ឌិត **កែ មុន្នីវុធ** នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ

៣. លោក **គង់ គា** នាយកដ្ឋានដំណាំស្រូវ។

## II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## III. អ្នកស្រាវជ្រាវ:

ក្រុមអ្នកបច្ចេកទេសនាយកដ្ឋានដំណាំស្រូវ និងនាយកដ្ឋានការពារដំណាំអនាម័យ និងភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម។

## IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. លោក **កុយ សារ៉េត** នាយកដ្ឋានការពារដំណាំ អនាម័យនិងភូតគាមអនាម័យ

២. លោក **អឿន សំអុល** នាយកដ្ឋានការពារដំណាំ អនាម័យនិងភូតគាមអនាម័យ

៣. លោក **យ៉ា នោគ** នាយកដ្ឋានការពារដំណាំ អនាម័យនិងភូតគាមអនាម័យ

៤. លោក **ជឹម ចាន់ណា** នាយកដ្ឋានការពារដំណាំ អនាម័យនិងភូតគាមអនាម័យ

៥. លោក **លួន ពិសី** នាយកដ្ឋានការពារដំណាំ អនាម័យនិងភូតគាមអនាម័យ

៦. លោក **ហុខ ឡូទី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់និងនេសាទ។

# លិខិតថ្លែងអំណរគុណ

ស្រូវ-អង្ករ គឺជាស្បៀងអាហារប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរ តាំងពីសម័យបុរាណមក ហើយស្រូវក៏ជាស្បៀងដ៏សំខាន់សម្រាប់មនុស្សនៅលើពិភពលោក ជាពិសេសនៅក្នុងទ្វីបអាស៊ី។ រាជរដ្ឋាភិបាលបានកំណត់ថា ស្រូវ-អង្ករ គឺជា មាសស របស់ប្រទេសកម្ពុជា សម្រាប់ការធ្វើពាណិជ្ជកម្មក្រៅប្រទេស។ តម្រូវការអង្ករមានការកើនឡើងជារៀងរាល់ឆ្នាំ បើតាមការព្យាករណ៍នៅឆ្នាំ២០៣៥ សម្រាប់ប្រជាជនលើពិភពលោកត្រូវការអង្ករប្រមាណ៥៥៣លានតោនក្នុង១ឆ្នាំ។

បច្ចុប្បន្នផលិតកម្មដំណាំស្រូវ របស់ប្រជាកសិករនៅក្នុងប្រទេសកម្ពុជានៅមានកម្រិត ទាំងគុណភាព និងបរិមាណ។ កត្តានេះពាក់ព័ន្ធនឹងកម្រិតចំណេះដឹងនៃផលិតកម្មនៅមានកម្រិត មិនទាន់បានអនុវត្តត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងកត្តាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដែលមិនអាចបំពេញតម្រូវការអ្នកប្រើប្រាស់ និងតម្រូវការទីផ្សារជាពិសេសស្របតាមតម្រូវការបទដ្ឋាននៃការនាំចេញស្រូវ-អង្ករអន្តរជាតិ។ផលិតកម្មដំណាំស្រូវត្រូវបានរាប់បញ្ចូលនូវបច្ចេកទេសជាច្រើនក្នុងនោះរួមមានៈ ការជ្រើសរើស និងរក្សាទុកដាក់គ្រាប់ពូជ បច្ចេកទេសដាំដុះ និងថែទាំ បច្ចេកទេសប្រមូលផល និងក្រោយប្រមូលផល ការកែច្នៃ ។ល។ ការប្រឈមខាងលើបានជះឥតពលយ៉ាងខ្លាំងដល់ផលិតកម្មដំណាំស្រូវ ជាពិសេសអាចនាំមកនូវវិបត្តិសេដ្ឋកិច្ចរបស់គ្រួសារប្រជាកសិករផងដែរ ដូចនេះតាមរយៈគម្រោងសន្តិសុខស្បៀង សម្រាប់កសិករក្រីក្របានរៀបចំនូវវគ្គបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ចំណេះដឹង និងបច្ចេកទេសផលិតកម្មដំណាំស្រូវដល់កសិករ និងអ្នកផលិត ជាពិសេសការជ្រើសរើសពូជ និងផលិតពូជស្រូវប្រកបដោយគុណភាពខ្ពស់ ដោយរួមបញ្ចូលទាំងទ្រឹស្តីតាមរយៈមេរៀន បទបង្ហាញការអនុវត្តជាក់ស្តែង ព្រមទាំងបានចងក្រងសៀវភៅបច្ចេកទេស គោលការណ៍ណែនាំ និងឯកសារវីដេអូបច្ចេកទេសស្តីពីផលិតកម្មពូជស្រូវ សម្រាប់បរិបទនៃប្រទេសកម្ពុជាផងដែរ។

ដោយមើលឃើញពីបញ្ហាដែលកំពុងជួបប្រទះ និងចូលរួមលើកកម្ពស់ផលិតកម្មពូជស្រូវនៅកម្ពុជា “ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ”

ដោយមានការជួយគាំទ្រថវិកា ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការរៀបចំចងក្រង និងបោះពុម្ពសៀវភៅណែនាំស្តីពី ផលិតកម្មពូជស្រូវ ដើម្បីជួយគាំទ្រដល់ប្រជាកសិករ ក្រុមផលិតពូជស្រូវ សហគមន៍កសិកម្ម ក្រុមហ៊ុនឯកជនផលិតពូជស្រូវក្នុងការអនុវត្តបច្ចេកទេស និងផលិតពូជស្រូវ ស្របតាមលក្ខណៈបច្ចេកទេស និងមានគុណភាពខ្ពស់ស្របតាមស្តង់ដារដែលបានកំណត់។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់រាជរដ្ឋាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានគាំទ្រដល់ការចងក្រង និងបោះពុម្ពសៀវភៅណែនាំស្តីពី ផលិតកម្មពូជស្រូវ នេះឡើង។ ពូជស្រូវល្អ គឺជាផ្នែកមួយនៃកំណើនសេដ្ឋកិច្ចគ្រួសារកសិករនៅមូលដ្ឋានពីព្រោះការការប្រើប្រាស់ពូជស្រូវសុទ្ធល្អ នាំឱ្យការលូតលាស់របស់ដំណាំស្រូវមានសុខភាពល្អ និងទទួលបានទិន្នផលខ្ពស់។

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា សៀវភៅណែនាំស្តីពី ផលិតកម្មពូជស្រូវ នេះនឹងផ្តល់ចំណេះដឹងការអនុវត្តល្អៗ និងគោលការណ៍បច្ចេកទេសជាមូលដ្ឋានសម្រាប់អ្នកពាក់ព័ន្ធយកទៅអនុវត្តដើម្បីលើកកម្ពស់គុណភាពគ្រាប់ពូជស្រូវឱ្យកាន់តែល្អប្រសើរស្របតាមស្តង់ដារដែលបានកំណត់។ លើសពីនេះទៀត ការប្រើប្រាស់គ្រាប់ពូជស្រូវមានគុណភាពល្អអាចជួយបង្កើនទិន្នផលស្រូវ គុណភាពអង្ករ ធ្វើឱ្យអ្នកផលិត និងអ្នកកែច្នៃទទួលបានផលចំណេញកាន់តែប្រសើរ។

ថ្ងៃអង្គារ ៥កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២ ខែសីហា ឆ្នាំ២០២២

**ប្រធាននាយកដ្ឋាន**
**ផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត. ម៉ៅ មិនា**

មាតិកា ទំព័រ


**១. សារចារ** ........ ០១

**២.ការចាត់ថ្នាក់គ្រាប់ពូជស្រូវ** ........ ០២

២.១ ការចាត់ថ្នាក់គ្រាប់ពូជស្រូវ ........ ០២

២.២ ស្តង់ដារគុណភាពគ្រាប់ពូជស្រូវ ........ ០៣

**៣. បច្ចេកទេសផលិតកម្មគ្រាប់ពូជស្រូវ** ........ ០៥

៣.១ ផែនការផលិតកម្មគ្រាប់ពូជស្រូវ ........ ០៥

៣.២ ការជ្រើសរើសទីតាំងស្រែផលិតកម្មពូជស្រូវ ........ ០៧

៣.៣ ការរៀបចំដី ........ ០៧

៣.៤ ការរៀបចំធ្វើថ្នាលសំណាប ........ ០៨

៣.៤.១ សំណាបថ្នាលសើម ........ ០៨

៣.៤.២ ការធ្វើថ្នាលដាប៉ុក ........ ១៣

៣.៥ ការស្ទូង ........ ១៣

៣.៦. ការជួសគុម្ព ........ ១៥

៣.៧. ការកម្ចាត់ពូជលាយ និងស្មៅ ........ ១៥

៣.៨ ការគ្រប់គ្រងទឹក ........ ១៧

៣.៩ ការគ្រប់គ្រងជាតិដី ........ ១៨

៣.១០. ការគ្រប់គ្រង់សត្វល្អិតចង្រៃ និងជំងឺ ........ ២០

៣.១១ ការងារប្រមូលផល ........ ២១

៣.១១.១. ការច្រូតកាត់ដោយដៃ ឬម៉ាស៊ីនច្រូតពាក់កណ្តាលស្វ័យប្រវត្តិ ........ ២១

៣.១១.២ ការច្រូតដោយម៉ាស៊ីនទំនើប ........ ២២

៣.១២. ប្រតិបត្តិការក្រោយការច្រូតកាត់ និងការកែច្នៃគ្រាប់ពូជ(នៅមជ្ឈមណ្ឌលកែច្នៃគ្រាប់ពូជ) ........ ២៣

មាតិកា ទំព័រ


៣.១២.១.ការបោកស្រូវ..................................................២៣
៣.១២.២. ការដឹកជញ្ជូន..................................................២៥
៣.១២.៣. ការសម្ងួត..................................................២៥
៣.១២.៤. ការសម្អាតគ្រាប់ពូជស្រូវ..................................................២៩
៣.១២.៥. ការវេចខ្ចប់..................................................៣១
៣.១២.៦. ការស្តុកគ្រាប់ពូជស្រូវ..................................................៣២
៣.១២.៧. ការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវ..................................................៣៤
៣.១២.៨. ស្លាកសម្គាល់គ្រាប់ពូជស្រូវ( ស្លាកសញ្ញាព័ត៌មាន ). ៣៦
៣.១២.៩. អ្នកផលិតគ្រាប់ពូជស្រូវ ..................................................៣៧
៣.១២.១០. កម្មវិធីផលិតគ្រាប់ពូជគ្រឹះ..................................................៣៧
៣.១២.១១. កម្មវិធីផលិតគ្រាប់ពូជចុះបញ្ជី..................................................៣៨
៣.១២.១២. កម្មវិធីផលិតគ្រាប់ពូជវិញ្ញាបនបត្រ..................................................៣៨
៣.១២.១៣. សាលារៀនស្រែកសិករសម្រាប់លើកកម្ពស់
ផលិតកម្មគ្រាប់ពូជ ..................................................៣៩




# សៀវភៅណែនាំស្តីពីផលិតកម្មគ្រាប់ពូជស្រូវ

## ១. សាវតារៈ

កសិកម្មនៅតែជាវិស័យសំខាន់ជាងគេក្នុងសេដ្ឋកិច្ចកម្ពុជាដោយបានរួមចំណែកជាមួយផលិតផលក្នុងស្រុកសរុប (GDP) ចំនួន ៣២% និងផ្តល់ការងារចំនួន ៦០% នៃកម្លាំងពលកម្ម។ ទន្ទឹមនឹងនេះ ប្រជាពលរដ្ឋចំនួន ៨០% ពឹងផ្អែកលើវិស័យកសិកម្មសម្រាប់ជីវភាពរស់នៅរបស់ខ្លួន។ វិស័យកសិកម្មគឺជាកម្លាំងជំរុញសំខាន់មួយដល់កំណើនសេដ្ឋកិច្ចដែលសម្រេចបាននូវកំណើនថេរក្នុងរយៈពេលចាប់ពីឆ្នាំ២០០២ ដល់២០១២។ នៅក្នុងវិស័យកសិកម្ម ស្រូវគ្របដណ្តប់ច្រើនជាង ៩០% នៃតំបន់ដាំដុះ ហើយការផលិតស្រូវភាគច្រើនបំផុតគឺសម្រាប់ការប្រើប្រាស់ក្នុងស្រុក។ អនុវិស័យស្រូវមានចំណែកប្រហែល ៥០% នៃទិន្នផលរបស់វិស័យកសិកម្ម។ ដោយសារតួនាទីចម្បងបំផុតនៃវិស័យនេះស្ថិតក្នុងវិស័យសេដ្ឋកិច្ច ការកែប្រែអនុវិស័យស្រូវពីរៀងបន្ទាប់បន្សំឱ្យទៅជាវិស័យតម្រង់ទិសទៅរកអាជីវកម្ម គឺជាជម្រើសយុទ្ធសាស្ត្រសម្រាប់ប្រទេសកម្ពុជាដោយសារតែអនុវិស័យនេះ អាចផ្តល់ឱកាសប្រសើរបំផុតដើម្បីលើកកម្ពស់សន្តិសុខស្បៀងថ្នាក់ជាតិ និងពង្រីកការនាំចេញស្រូវ អង្ករដែលជាលទ្ធផលនៃការកាត់បន្ថយភាពក្រីក្រ។

ដោយបានស្គាល់អំពីឱកាសពិសេសដែលមាននៅក្នុងអនុវិស័យស្រូវសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវបំណងរបស់ខ្លួនតាមរយៈគោលនយោបាយស្រូវដើម្បីកែប្រែប្រទេសកម្ពុជាឱ្យទៅជា “ ជង្រុកស្រូវ ” ហើយក្លាយជាប្រទេសនាំចេញដែលខ្លួនបានកំណត់នៅក្រោមគោលនយោបាយស្រូវអង្ករនោះឡើយ ពោលគឺការនាំចេញអង្ករឱ្យបានមួយលានតោន។ ដូច្នេះហើយទើបបានជាមានការផ្តោតការយកចិត្តទុកដាក់សារជាថ្មីពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាលើការកែលម្អការផ្គត់ផ្គង់ និងការគ្រប់គ្រងទឹក ហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារសម្ងួត និងឃ្លាំង ការផ្សារភ្ជាប់

ទំនាក់ទំនងទីផ្សារ ហើយសំខាន់បំផុតនោះគឺការធ្វើឱ្យមានគ្រាប់ពូជគុណភាពសម្រាប់ផលិតកម្មស្រូវ។

ដោយយល់ឃើញពីសារៈសំខាន់ និងភាពចាំបាច់ខាងលើ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយនាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម បានរៀបចំកូនសៀវភៅណែនាំស្តីពីបច្ចេកទេសផលិតពូជស្រូវនេះឡើងក្នុងគោលបំណងផ្តល់ជូនជាចំណេះដឹងបន្ថែម ដល់ប្រជាកសិករ ក្រុមហ៊ុន ដៃគូអភិវឌ្ឍ ដែលមានមុខរបរ ពាក់ព័ន្ធនឹងវិស័យកសិកម្ម យកទៅអនុវត្តដើម្បីជំរុញផលិតកម្មរបស់ខ្លួន ឱ្យកាន់តែមានភាពរីកចំរើនមួយកម្រិតទៀត។

## ២.ការចាត់ថ្នាក់គ្រាប់ពូជស្រូវ៖

### ២.១ ការចាត់ថ្នាក់គ្រាប់ពូជស្រូវ:

កន្លងមកនៅប្រទេសកម្ពុជា ខណៈដែលឧស្សាហកម្មគ្រាប់ពូជស្ថិតក្នុងដំណាក់កាលអភិវឌ្ឍនៅឡើយ។ ជាធម្មតាគ្រាប់ពូជស្រូវត្រូវបានចាត់ថ្នាក់ជា ៥ ប្រភេទខុសៗគ្នា អាស្រ័យលើជំនាន់របស់គ្រាប់ពូជ លក្ខខណ្ឌ និងការថែទាំក្នុងការផលិត ភាពសុទ្ធរបស់គ្រាប់ពូជ និងគោលបំណងនៃការផលិត។ ដូច្នេះ បច្ចុប្បន្ន ការចាត់ថ្នាក់គ្រាប់ពូជស្រូវនៅប្រទេសកម្ពុជាមានដូចខាងក្រោម៖

- គ្រាប់ពូជមេ (Nucleus seed)៖ សំដៅដល់គ្រាប់ពូជស្រូវដែលត្រូវបានផលិត និង រក្សាទុកដោយរុក្ខជម្រើសវិទូ ហើយមិនមែនជាគ្រាប់ពូជស្រូវសម្រាប់ធ្វើពាណិជ្ជកម្មទេ។

- គ្រាប់ពូជជម្រើសវិទូ (Breeder seed)៖ សំដៅដល់គ្រាប់ពូជស្រូវដែលត្រូវបានផលិតដោយរុក្ខជម្រើសវិទូដោយប្រើប្រាស់គ្រាប់ពូជស្រូវមេ ដាំជាជួរ និងប្រើក្បួរស្រូវដែលបានប្រមូលពីពូជស្រូវមេ ហើយទទួលស្គាល់ពីស្ថាប័នដើមដែលជាអ្នកបង្កើតប្រភេទពូជស្រូវនេះមុនគេ។ គ្រាប់ពូជស្រូវជម្រើសវិទូជាប្រភេទសម្រាប់ផលិតគ្រាប់ពូជស្រូវនៃចំណាត់ថ្នាក់ដទៃទៀត ជាពិសេសសម្រាប់ផលិតកម្មគ្រាប់ពូជស្រូវគ្រឹះ។

- គ្រាប់ពូជគ្រឹះ ( Foundation seed )៖ សំដៅដល់គ្រាប់ពូជស្រូវដែលផលិតដោយរុក្ខជម្រើសវិទូដោយប្រើប្រាស់គ្រាប់ពូជជម្រើសវិទូ ស្ទូងជាជួរ១ដើមក្នុង១គុម្ព ឬដាំ១គ្រាប់ក្នុង១គុម្ព ក្រោមការត្រួតពិនិត្យផ្ទាល់ពីម្ចាស់ពូជ។ គ្រាប់ពូជគ្រឹះត្រូវបានផលិតក្រោមវិធានការដែលបង្កើតដោយអង្គភាពបញ្ជាក់គុណភាពពូជដំណាំក្នុងគោលបំណងរក្សាភាពសុទ្ធពិន្ទុ និងអត្តសញ្ញាណរបស់ប្រភេទពូជស្រូវ។

- គ្រាប់ពូជចុះបញ្ជី ( Registered seed )៖ សំដៅដល់គ្រាប់ពូជស្រូវដែលត្រូវបានផលិតដោយប្រើប្រាស់គ្រាប់ពូជគ្រឹះ ដោយត្រូវដាំជាជួរក្រោមវិធានដែលមានការទទួលស្គាល់ពីអង្គភាពបញ្ជាក់គុណភាពពូជដំណាំ ដើម្បីរក្សាភាពសុទ្ធពិន្ទុ និងអត្តសញ្ញាណរបស់ប្រភេទពូជ។

- គ្រាប់ពូជវិញ្ញាបនបត្រ ( Certified seed )៖ សំដៅដល់គ្រាប់ពូជដំណាំដែលត្រូវបានផលិតដោយប្រើប្រាស់ពូជដំណាំចុះបញ្ជីក្រោមវិធានដែលមានការទទួលស្គាល់ពីអង្គភាពបញ្ជាក់គុណភាពពូជដំណាំដើម្បីរក្សាភាពសុទ្ធពិន្ទុ និងអត្តសញ្ញាណរបស់ប្រភេទពូជ។

## ២.២ ស្តង់ដារគុណភាពគ្រាប់ពូជស្រូវ

ផែនការផលិតគ្រាប់ពូជគ្រឹះ គ្រាប់ពូជចុះបញ្ជី និង គ្រាប់ពូជវិញ្ញាបនបត្រតាមរយៈកិច្ចព្រមព្រៀងជាមួយនឹងអ្នកផលិតគ្រាប់ពូជស្រូវនានាដូចជា៖ CARDI កសិដ្ឋាន ឬស្ថានីយ៍កសិកម្មដែលបានជ្រើសរើស សហគមន៍កសិកម្ម និងក្រុមកសិករផលិតគ្រាប់ពូជស្រូវនៅតាមខេត្តគោលដៅ។ ប៉ុន្តែសម្រាប់ការផលិតក្នុងទំហំច្រើននៃគ្រាប់ពូជស្រូវ នឹងផ្តោតលើការផលិតគ្រាប់ពូជចុះបញ្ជី និង គ្រាប់ពូជវិញ្ញាបនបត្រប៉ុណ្ណោះ សម្រាប់លក់ទៅឱ្យកសិករ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកទិញលក់គ្រាប់ពូជស្រូវផ្សេងទៀត។ស្តង់ដារគុណភាពសម្រាប់ទីវាលស្រែផលិតពូជនិងប្រភេទគ្រាប់ពូជស្រូវនីមួយៗត្រូវបញ្ជាក់តាមឯកសារ“ ស្តង់ដារគ្រាប់ពូជស្រូវ និងនីតិវិធីវាយតម្លៃគុណភាព ” ដែលមានចែងដូចខាងក្រោម៖

## ស្តង់ដារស្រែអប្បបរមាសម្រាប់ផលិតកម្មគ្រាប់ពូជស្រូវ

| កត្តា | ចំនួនអតិបរមានៃរុក្ខជាតិលើដី ១០០ម២ | | |
| --- | --- | --- | --- |
| | គ្រាប់ពូជគ្រឹះ | គ្រាប់ពូជចុះបញ្ជី | គ្រាប់ពូជវិញ្ញាបនបត្រ |
| ១.ការលាយពូជស្រូវផ្សេង(គុម្ព) | ០ | ១ | ២ |
| ២.ស្មៅហាមឃាត់(គុម្ព) | ០ | ៥ | ១០ |

**សម្គាល់:** ស្មៅដែលហាមឃាត់រួមមាន៖

- ស្មៅបែកក្បាល (Echinochloa sp.)
- កក់ឆ័ត្រ (Cyperus iria)
- ស្មៅកន្ទុយក្ងោក (Leptocloa Chinensis)

## ស្តង់ដារគ្រាប់ពូជស្រូវតាមចំណាត់ថ្នាក់

| កត្តា | ស្តង់ដារគ្រាប់ពូជស្រូវតាមចំណាត់ថ្នាក់នីមួយៗ | | |
| --- | --- | --- | --- |
| | គ្រាប់ពូជគ្រឹះ | គ្រាប់ពូជចុះបញ្ជី | គ្រាប់ពូជវិញ្ញាបនបត្រ |
| ១. គ្រាប់ពូជសុទ្ធ(%អប្បបរមា) | ៩៨ | ៩៨ | ៩៨ |
| ២. កម្ទេចកម្ទី(%អតិបរមា) | ២ | ២ | ២ |
| ◆ គ្រាប់ស្មៅ(ចំនួនគ្រាប់អតិបរមាក្នុង៥០០ក្រាមគ្រាប់ពូជ) | ៣ | ៥ | ១០ |
| ◆ គ្រាប់ដំណាំដទៃ(ចំនួនគ្រាប់អតិបរមាក្នុង៥០០ក្រាមគ្រាប់ពូជ) | ២ | ៣ | ៥ |
| ◆ គ្រាប់ស្រូវផ្សេងៗ(ចំនួនគ្រាប់អតិបរមាក្នុង៥០០ក្រាមគ្រាប់ពូជ) | ១ | ៥ | ១៥ |
| ◆ គ្រាប់អង្ករក្រហម(ចំនួនគ្រាប់អតិបរមាក្នុង៥០០ក្រាមគ្រាប់ពូជ) | ០ | ២ | ៥ |
| ៣. ដំណុះគ្រាប់(%អប្បបរមា) | ៨៥ | ៨៥ | ៨០ |
| ៤. សំណើមគ្រាប់(%អតិបរមា) | ១២ | ១៣ | ១៤ |
| | | | |

គួរកត់សម្គាល់ថា ស្តង់ដារគ្រាប់ពូជគ្រប់ចំណាត់ថ្នាក់គឺស្ទើរតែដូចគ្នាទាំងអស់ លើកលែងតែចំណុចខុសគ្នាសំខាន់ៗនៃជំនាន់របស់វា។ គ្រាប់ពូជដែលផលិតឡើងត្រូវ

មានគុណភាពល្អ គោរពតាមស្តង់ដារកំណត់ដូចបានបញ្ជាក់ខាងលើ ត្រូវវេចខ្ចប់នៅក្នុងបាវត្រឹមត្រូវដែលមានស្លាកសញ្ញាសម្គាល់ ដូចបានចែងក្នុងចំណុច ៣.១២.៥ ហើយត្រូវរក្សាទុកឱ្យបានត្រឹមត្រូវតាមបច្ចេកទេសដូចមានចែងក្នុងចំណុច ៣.១២.៦។ កម្រិតស្តង់ដារសម្រាប់គ្រាប់ពូជស្រូវនេះ ត្រូវបានប្រើប្រាស់គ្រប់តួអង្គពាក់ព័ន្ធនៅក្នុងផលិតកម្មគ្រាប់ពូជស្រូវ។ រាល់ផលិតកម្មគ្រាប់ពូជត្រូវមានការត្រួតពិនិត្យ វាយតម្លៃ និងផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពមុននឹងអនុញ្ញាតឱ្យប្រើប្រាស់ និងធ្វើអាជីវកម្មលើទីផ្សារ។ ដូច្នេះ ត្រូវសហការជាមួយអគ្គនាយកដ្ឋានកសិកម្មក្នុងការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវ ផ្តល់វិញ្ញាបនបត្រស្របតាមស្តងដារគុណភាពគ្រាប់ពូជស្រូវដែលបានផលិត។

## ៣. បច្ចេកទេសផលិតកម្មគ្រាប់ពូជស្រូវ

ការផលិតគ្រាប់ពូជស្រូវមានបំណងផលិតគ្រាប់ពូជស្រូវដែលមានគុណភាពសមស្របតាមស្តង់ដារសម្រាប់ផ្គត់ផ្គង់ទៅឱ្យកសិករ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកទិញគ្រាប់ពូជស្រូវដទៃទៀត។ ក្នុងចំណោមការងារនានា ការផលិតគ្រាប់ពូជស្រូវផ្តោតលើការរក្សាបាននូវភាពសុទ្ធពិន្ទុរបស់ប្រភេទពូជដែលត្រូវផលិតពង្រីក។ ដើម្បីធានាបាននូវគុណភាពរបស់គ្រាប់ពូជស្រូវ អ្នកផលិតត្រូវគោរពតាមបច្ចេកទេសផលិតកម្មគ្រាប់ពូជស្រូវ ដូចមានបង្ហាញខាងក្រោម៖

### ៣.១ ផែនការផលិតកម្មគ្រាប់ពូជស្រូវ

ត្រូវរៀបចំផែនការផលិតគ្រាប់ពូជស្រូវប្រចាំឆ្នាំដោយពិចារណាលើចំណុចដូចខាងក្រោម៖

- ត្រូវធ្វើការវាយតម្លៃតម្រូវការទីផ្សារ និងការបញ្ជាទិញគ្រាប់ពូជស្រូវពីអ្នកទិញនានា( ឧទាហរណ៍:កសិករ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកទិញគ្រាប់ពូជស្រូវដទៃទៀត )
- ត្រូវធ្វើការកំណត់ប្រភេទពូជ និងគុណភាពរបស់គ្រាប់ពូជស្រូវដែលត្រូវផលិត ដោយផ្អែកលើការបញ្ជាទិញពីអ្នកទិញផ្សេងៗ( ត្រូវកំណត់ឱ្យច្បាស់ថា តើប្រភេទពូជមួយណាដែលមានតម្រូវការខ្ពស់មានតម្រូវការមធ្យម និងមានតម្រូវការតិច )

- ត្រូវផ្គត់ផ្គង់គ្រាប់ពូជតាមតម្រូវការរបស់អ្នកទិញទាំងបរិមាណ គុណភាព និងការបញ្ជូនទំនិញឱ្យទាន់ពេលវេលា
- ត្រូវធ្វើផែនការបញ្ចប់ជាស្ថាបពរ និងបញ្ជូនផែនការផលិតកម្មសម្រាប់គ្រាប់ពូជស្រូវ ប្រភេទ ចំណាត់ថ្នាក់ខុសៗគ្នាឱ្យបានមួយឆ្នាំ ឬមួយរដូវជាមុន ពោលគឺមុនពេលចាប់ផ្តើមរដូវផលិតឱ្យទៅភាគីចុះកិច្ចសន្យាផលិត( មើលតារាងទី២៖ផែនការផលិតកម្មគ្រាប់ពូជស្រូវ )
- ត្រូវធ្វើការរៀបចំកាលវិភាគសម្រាប់ការដាំដុះដំណាំស្រូវទៅតាមប្រភេទពូជ និងរដូវកាលដាំដុះសម្រាប់ការផលិតគ្រាប់ពូជស្រូវនាឆ្នាំបន្ទាប់( សូមមើលតារាងទី១ )។

## តារាងទី១៖រដូវកាលផលិតគ្រាប់ពូជស្រូវ

| រដូវដាំដុះ | ពេលវេលានៃសកម្មភាពដាំដុះ(ខែ) | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ស្រូវដើមរដូវវស្សា | x | x | x | x | x | x | x | x | | | | |
| ស្រូវរដូវវស្សា | | | | | | x | x | x | x | x | x | x |
| ស្រូវរដូវប្រាំង | | | | | | | | | x | x | x | x |

## តារាងទី២៖តារាងផែនការផលិតកម្មគ្រាប់ពូជស្រូវ

| ស្ថានីយកសិកម្ម............... | | | ផែនការផលិតកម្មគ្រាប់ពូជស្រូវឆ្នាំ................ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| រដូវដាំដុះ | ប្រភេទពូជទី១ .................... | | | | ប្រភេទពូជទី២ .................... | | | | ប្រភេទពូជទី៣ .................... | | | | សរុប | | | |
| | គ្រាប់ពូជចុះបញ្ជី | | គ្រាប់ពូជវិញ្ញាបនបត្រ | | គ្រាប់ពូជចុះបញ្ជី | | គ្រាប់ពូជវិញ្ញាបនបត្រ | | គ្រាប់ពូជចុះបញ្ជី | | គ្រាប់ពូជវិញ្ញាបនបត្រ | | គ្រាប់ពូជចុះបញ្ជី | | គ្រាប់ពូជវិញ្ញាបនបត្រ | |
| | ហ.ត | តោន | ហ.ត | តោន | ហ.ត | តោន | ហ.ត | តោន | ហ.ត | តោន | ហ.ត | តោន | ហ.ត | តោន | ហ.ត | តោន |
| ស្រូវដើមរដូវវស្សា | | | | | | | | | | | | | | | | |
| ស្រូវរដូវវស្សា | | | | | | | | | | | | | | | | |
| ស្រូវរដូវប្រាំង | | | | | | | | | | | | | | | | |
| សរុប | | | | | | | | | | | | | | | | |

### ៣.២ ការជ្រើសរើសទីតាំងស្រែផលិតកម្មពូជស្រូវ

ដើម្បីឱ្យដំណើរការផលិតកម្មគ្រាប់ពូជស្រូវទទួលបានជោគជ័យ និងមានគុណភាពស្របតាមស្តង់ដារសហគមន៍ផលិតពូជស្រូវត្រូវធ្វើការជ្រើសរើសទីតាំង និងប្រភេទដីស្រែដែលមានលក្ខណៈសម្បត្តិពិសេសដូចខាងក្រោម៖

- ត្រូវជ្រើសរើសដីស្រែសម្រាប់ផលិតគ្រាប់ពូជ មានសុវត្ថិភាពលើគ្រោះធម្មជាតិនានា ដូចជាទឹកជំនន់ គ្រោះរាំងស្ងួត
- ដីមានជីជាតិល្អ
- ដីពុំមានលក្ខណៈផ្តល់ឱកាសល្អដល់កត្តាចង្រៃ ដូចជា៖សត្វល្អិត និងជំងឺ
- ដីមានប្រភពទឹកអាចមានលទ្ធភាពក្នុងការស្រោចស្រពបាន
- ត្រូវរៀបចំផ្ទៃដីស្រែនីមួយៗឱ្យមានទំហំសមស្របចាប់ពី ០.២៥ ហ.ត (៥០ម x ៥០ម)ឡើងទៅ។ គួររំលាយស្រែតូចៗបញ្ចូលគ្នា ហើយកៀរដីឱ្យស្មើល្អដើម្បីងាយស្រួលក្នុងការភ្ជួររាស់ និងគ្រប់គ្រងទឹកក្នុងស្រែបានល្អ។

### ៣.៣ ការរៀបចំដី

ការរៀបចំដី គឺជាកត្តាដ៏សំខាន់បំផុតមួយដែលជះឥទ្ធិពលទៅលើការលូតលាស់របស់ដំណាំស្រូវ។ ដីដែលរៀបចំបានល្អដោយការភ្ជួររាស់ត្រឡប់ជញ្រ្ជាំងស្រូវ និងស្មៅចូលទៅក្នុងដី នាំឱ្យមានការបង្កើនជីជាតិ និងជួយរក្សាគុណភាពដីដែលជំរុញការលូតលាស់របស់ដំណាំស្រូវបានល្អ។ ជាពិសេសប្រព័ន្ធឫសមានសមត្ថភាពកាន់តែប្រសើរក្នុងការទាញយកសារជាតិចិញ្ចឹមពីក្នុងដីបានច្រើន។ ជាងនេះទៅទៀត ការរៀបចំដីបានត្រឹមត្រូវមានទំនាក់ទំនងជាវិជ្ជមានជាមួយនឹងប្រសិទ្ធភាពក្នុងការប្រើប្រាស់ទឹកសម្រាប់ដំណាំ និងការកាត់បន្ថយវត្តមានសត្វល្អិត ស្មៅ និងជំងឺផងដែរ។ ការរៀបចំដីបានល្អត្រូវអនុវត្តតាមចំណុចមួយចំនួនដូចខាងក្រោម៖

- ទីតាំងស្រែសម្រាប់ផលិតគ្រាប់ពូជស្រូវ ត្រូវជ្រើសរើសទីតាំង ដែលមានជីជាតិ នៅជិតប្រភពទឹកពុំមានហានិភ័យគ្រោះធម្មជាតិ
- ត្រូវកៀរពង្រាបដីស្រែសម្រាប់ផលិតកម្មគ្រាប់ពូជស្រូវឱ្យបានល្អ

- ត្រូវភ្ជួរដីយ៉ាងតិចពីរដង និងត្រូវរាស់ដីឱ្យបានសព្វ។ ធ្វើដូច្នេះជួយកម្ចាត់ស្មៅ និងផ្លាស់ប្តូរស្រទាប់ដីបានល្អ

- មិនត្រូវភ្ជួរដីជ្រៅពេក ឬរាក់ពេកទេ។ ជម្រៅនៃការភ្ជួរគឺអាស្រ័យលើប្រភេទដី។ ឧទាហរណ៍៖ សម្រាប់ដីល្បាយខ្សាច់ គួរភ្ជួរជម្រៅ ១០-១៥ស.ម និងដីល្បាយឥដ្ឋ គួរភ្ជួរជម្រៅ ១៥-២៥ស.ម

- ត្រូវភ្ជួរលើកទី១ឱ្យបានឆាប់បន្ទាប់ពីការប្រមូលផលដំណាំស្រូវ ពីព្រោះអំឡុងពេលនេះដីនៅសើម ហើយសំណល់រុក្ខជាតិ និងស្មៅត្រូវបានកប់នៅក្នុងដីទាំងស្រុង ព្រមទាំងកម្ចាត់សមាសភាពចង្រៃផងដែរ

- ត្រូវភ្ជួរលើកទី២ធ្វើឡើងក្នុងអំឡុងពេល១-២ដង/សប្តាហ៍មុនពេលស្ទូងដើម្បីទប់ស្កាត់ការលូតលាស់របស់ស្មៅ និងជួយពន្លឿនការរលួយស្មៅ

- ត្រូវរាស់ដីឱ្យសព្វដើម្បីងាយស្រួលក្នុងការស្ទូង

- ត្រូវរៀបចំដីស្រែផលិតកម្មពូជស្រូវឱ្យមានភ្លឺត្រឹមត្រូវទើបរក្សាទឹកបានសមស្រប និងកម្ពស់ទឹកក្នុងស្រែស្មើគ្នាល្អ មិនមានស្មៅច្រើនហើយស្រូវដុះបានល្អ។

## ៣.៤ ការរៀបចំធ្វើថ្នាលសំណាប

### ៣.៤.១ សំណាបថ្នាលសើម

សំណាបដែលមានសុខភាពល្អ មានសារសំខាន់សម្រាប់ការផលិតគ្រាប់ពូជស្រូវ ពីព្រោះសំណាបនេះធានា ឬកំណត់ដល់ការលូតលាស់របស់ដំណាំស្រូវ និងទិន្នផល។ មានន័យថា ពូជសុទ្ធល្អ សំណាបល្អ សន្ទូងល្អ ទិន្នផលខ្ពស់។ ដើម្បីទទួលបានសំណាបមានគុណខ្ពស់ ត្រូវអនុវត្តតាមចំណុចមួយចំនួនដូចខាងក្រោម៖

#### កម្រិតប្រើប្រាស់គ្រាប់ពូជ

- ត្រូវប្រើបាស្រ់គ្រាប់ពូជស្រូវក្នុងកម្រិត ២០-៣០ គ.ក្រ ក្នុង១ហ.ត សម្រាប់ស្រែសន្ទូង។

#### ការជ្រើសរើសទីតាំង និងការធ្វើថ្នាលសំណាប

- ត្រូវជ្រើសរើសទីតាំងដីដែលមានជីជាតិខ្ពស់ជិតប្រភពទឹកសម្រាប់ធ្វើថ្នាល

សំណាប

- ត្រូវជ្រើសរើសទីតាំងដែលមានសុវត្ថិភាពពីគ្រោះធម្មជាតិ និងអាចការពារបានពីការបផ្លិចបំផ្លាញពីសត្វពាហនៈ
- ត្រូវចៀសវាសការជ្រើសរើសទីតាំងថ្នាលសំណាបក្បែរ ឬក្រោមម្លប់
- ត្រូវជ្រើសរើសទីតាំងថ្នាលសំណាបកុំឱ្យមានទឹកហូរកាត់ខ្លាំងនៅពេលមានភ្លៀងធ្លាក់ដែលធ្វើឱ្យរមូខូចសំណាប និងហូរនាំជីជាតិដីចេញទៅក្រៅ
- ត្រូវភ្ជូររាស់ដីថ្នាលសំណាបឱ្យបានច្រើនសារ(២-៣សារ) ដើម្បីសម្លាប់ស្មៅ សត្វល្អិត និងបំភាយសារធាតុពុលដើម្បីធ្វើឱ្យដីមានខ្យល់ចេញចូលគ្រប់គ្រាន់
- ត្រូវធ្វើថ្នាលក្នុងទំហំជាមធ្យមចំពោះទទឹង ១-១,៥ម និងបណ្តាលអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងនៃទីតាំង តែមិនត្រូវលើស២០ ម និងកម្ពស់១០-១៥ស.ម
- ត្រូវលាយលាមកគោ ឬជីកំប៉ុស្តជាមួយនឹងដី ដាក់ទ្រាប់បាត ដោយពង្រាយឱ្យបានស្មើល្អក្នុងកម្រិត ២ គ.ក្រ ក្នុង១ម²
- ត្រូវចៀសវាងការប្រើបាស្រ់ជីកំប៉ុស្ត និងជីធម្មជាតិផ្សេងទៀតដែលមានលាយទ្បំគ្រាប់ស្មៅ និងគ្រាប់ស្រូវប្រភេទផ្សេងទៀតដែលធ្វើឱ្យមានការធ្លាក់ចុះភាពសុទ្ធនៃគ្រាប់ពូជ។

### ការត្រាំ និងផ្អាប់គ្រាប់ពូជ

- ត្រូវត្រួតពិនិត្យប្រភេទពូជ ចំណាត់ថ្នាក់ និងគុណភាពគ្រាប់ពូជមុនពេលត្រាំផ្អាប់
- ត្រូវពិនិត្យភាពសុទ្ធ សំណើមគ្រាប់ កម្ទេចកម្ទី គ្រាប់ស្មៅ និងដំណុះគ្រាប់មុនចាក់ត្រាំថាតើស្របតាមស្តង់ដារដែរឬទេ?
- ត្រូវយកលទ្ធផលដំណុះពីផ្នែកគ្រប់គ្រងគុណភាព(ឃ្លាំង)ដើម្បីដឹងថាតើគ្រាប់ពូជមានគុណភាពស្របតាមស្តង់ដារឬទេ? ហើយត្រូវប្រាកដថា គ្រាប់ពូជដែលយកមកធ្វើការដាំដុះពិតជាមាន គុណភាពស្របតាមស្តង់ដារ
- ត្រូវអានសៀវភៅបង្គុំបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវ សម្រាប់ការធ្វើ

តេស្តដំណុះគ្រាប់ពូជស្រូវ

- ត្រូវហាលគ្រាប់ពូជស្រូវដោយកម្ដៅថ្ងៃរយៈពេល ២-៣ ម៉ោង ឬដោយត្រាំទឹកក្ដៅកម្រិត ៥២ អង្សាសេក្នុងរយៈពេល ១០-១៥ នាទី រួចស្រង់ឡើងវិញដើម្បីជាស់ដំណោកគ្រាប់ពូជស្រូវ សម្លាប់បាក់តេរី និងមេរោគដែលបង្កជំងឺដល់ដំណាំស្រូវ

- ត្រូវលាងសម្អាតគ្រាប់ពូជដោយទឹក និងស្រង់យកកម្ទេចកម្ទី និងគ្រាប់ពូជស្កកចេញមុនពេលត្រាំទឹក

- ត្រូវត្រាំគ្រាប់ពូជនឹងទឹកធម្មតារយៈពេលពី ២៤ម៉ោង រួចស្រង់ឡើងលាងសម្អាត វេចខ្ចប់ ឬគ្របឱ្យជិត ទុកដាក់ក្នុងទីកន្លែងម្លប់រយៈពេលពី ២៤-៣៨ ម៉ោង មានន័យថា ផ្អាប់គ្រាប់ពូជស្រូវដើម្បីឱ្យដុះបានល្អ

- ត្រូវពិនិត្យមើល ២-៣ ដងក្នុង១ថ្ងៃ អំឡុងពេលផ្អាប់គ្រាប់ពូជ។ បើដឹងថាមានកម្ដៅកើនឡើងខ្លាំង ត្រូវបើកគម្រប រួចជ្រាវឱ្យសព្វដើម្បីបន្ថយកម្ដៅ ហើយបើស្ងួត ឬខ្វះសំណើម ត្រូវប្រោះទឹករួចគ្របទៅវិញ។ ធ្វើរបៀបនេះរហូតសង្កេតឃើញថា គ្រាប់ពូជស្រូវដុះស្មើល្អអាចយកទៅសាបបាន។

### ការសាប

ដើម្បីឱ្យការសាបសំណាបបានល្អ និងសំណាបដុះលូតលាស់បានល្អ ត្រូវអនុវត្តតាមចំណុចសំខាន់មួយចំនួនដូចខាងក្រោម៖

- គ្រាប់ពូជដុះល្អមានលក្ខណៈដូចជា៖ ពន្លកថ្លោសល្អមានប្រវែង ០,៣-១ ស.ម និងមានឫសថ្លោសល្អមានប្រវែង ០,៥-១,៥ ស.ម ហើយមិនត្រូវទុកឱ្យគ្រាប់ស្រូវដុះពន្លក និងឫសវែងពេកទេពីព្រោះវាធ្វើឱ្យពិបាកសាប និងរងការខូចខាតគ្រាប់ពូជលើថ្នាលសំណាប

- ត្រូវប្រើបាស្រ់កម្រិតគ្រាប់ពូជស្រូវសម្រាប់ការសាបគឺ ០.០៥-០,១ គ.ក្រ (០,៥-១ខាំ) ក្នុង១ ម$^{២}$។

កម្រិតនៃការសាបនេះធ្វើឱ្យសំណាបដុះរង្វើល និងមានដើមដងថ្លោសល្អ

- ត្រូវប្រើគ្រាប់ពូជស្រូវពី ២០-៣០ គ.ក្រ សម្រាប់ការស្ទូងផ្ទៃដី ១ ហ.ត និង

ត្រូវការថ្នាលសំណាបទំហំពី ១៥០-២០០ ម²។




រូបភាពទី១៖ ដើមស្រូវស្ថិតក្នុងដំណាក់កាលដុះពន្លកដែលមានលក្ខណៈល្អគ្រប់គ្រាន់




រូបភាពទី២៖ការវិវឌ្ឍនៃដើមស្រូវក្នុងដំណាក់កាលដុះពន្លក

 

រូបភាពទី៣៖ ការរៀបចំថ្នាលសំណាប និងការសាប

- ត្រូវយកចិត្តទុកដាក់គិតគូរអំពីអាយុរបស់សំណាប ដោយយោងតាមប្រភេទពូជ និងលក្ខខណ្ឌអាកាសធាតុ។ អាយុសំណាបល្អបំផុតសម្រាប់ស្ទូងមានបញ្ជាក់ដូចខាងក្រោម៖
  - ១៥-២០ ថ្ងៃសម្រាប់ពូជស្រូវស្រាល
  - ២០-២៥ ថ្ងៃសម្រាប់ពូជស្រូវកណ្ដាល
  - ២៥-៣០ ថ្ងៃសម្រាប់ពូជស្រូវធ្ងន់
- ត្រូវអនុវត្តតាមសភាពការជាក់ស្ដែងដែលក្នុងករណីខ្លះលក្ខខណ្ឌធម្មជាតិមិនអំណោយផលដូចជា៖គ្មានភ្លៀងធ្លាក់ គ្មានទឹកក្នុងស្រែសម្រាប់ស្ទូង ឬទឹកជំនន់លិចជនអូសបន្លាយពេលវេលា។ ចំនួនថ្ងៃដែលបញ្ជាក់ខាងលើអាចមានការប្រែប្រួល និងមិនអាចត្រូវបានអនុវត្តតាមទាំងស្រុងឡើយ
- ត្រូវស្ទូងសំណាបខ្ចី និងសុខភាពល្អនឹងជួយឱ្យសន្ទូងលូតលាស់លឿនល្អជាងការប្រើសំណាបចាស់
- ត្រូវជផុះយកសំណាបដែលគ្មានឫស និងមានទំហំតូចៗចេញនៅពេលដកដើម្បីជៀសវាងយកសំណាកមិនល្អទៅស្ទូង នាំឱ្យដំណាំស្រូវដុះលូតលាស់មិនខ្លាំង និងមិនស្មើគ្នាល្អ
- មិនត្រូវចងកណ្ដាប់សំណាបដោយរឹតតឹងខ្លាំងពេកនោះទេ ពីព្រោះវាអាចធ្វើឱ្យមានការបាក់គ្រិចដើមសំណាប
- ត្រូវកាត់ចុងសំណាបចេញ ក្នុងករណីសំណាបមានវត្តមានសត្វល្អិតចង្រៃ

ធ្វើយ៉ាងនេះដើម្បីងាយស្រួលក្នុងការកាត់ពូជលាយ កម្ចាត់ស្មៅ និងធ្វើឱ្យពន្លឺ និងខ្យល់ចេញចូលបានគ្រប់គ្រាន់។





រូបភាពទី៤៖ ការស្ទូងជាជួរដោយប្រើខ្សែបន្ទាត់

ប្រសិនបើកម្លាំងពលកម្មមានកម្រិត ឬការជួលកម្លាំងពលកម្មថ្លៃ ការដាំដុះដោយវិធីសាស្ត្រដាំគ្រាប់អាចប្រើប្រាស់ឧបករណ៍ព្រោះ ឬឧបករណ៍ដាំជាជួរ( Drum Seeder/ Direct Rice Seeders)។ ទោះយ៉ាងណាក៏ដោយ ការប្រើប្រាស់ម៉ាស៊ីនដាំជាជួរ ឬឧបករណ៍ជាជួរ តម្រូវឱ្យមាន៖

- ការរៀបចំដីឱ្យបានល្អ ជាពេសិសការពង្រាបដី
- ការរៀបចំប្រព័ន្ធស្រោចស្រពឱ្យបានល្អ
- ការប្រើប្រាស់គ្រាប់ពូជស្រូវច្រើនជាងស្ទូងបន្តិច
- ត្រូវយកចិត្តទុកដាក់លើការកម្ចាត់ពូជលាយ និងស្មៅក្នុងស្រែផលិតពូជ។



រូបទី៥៖ការដាំគ្រាប់ពូជដោយម៉ាស៊ីនដាំជាជួរ



រូបទី៦៖ការដាំស្រូវដោយប្រើឧបករណ៍ព្រោះ

### ៣.៦. ការជួសគុម្ព

ការជួសគុម្ពធ្វើឡើងចំពោះការផលិតពូជស្រូវដោយស្ទូង។ ពេលស្ទូងរួច ត្រូវរក្សាទុកសំណាបជាបាច់តូចៗប្រហែល៥០ដើមក្នុង១បាច់ៗ រួចដាក់ក្បែរភ្លឺស្រែក្រោយស្ទូងរួច។ ក្នុងរយៈពេល ៣-៥ ថ្ងៃ ក្រោយស្ទូងត្រូវដើរពិនិត្យមើលគុម្ពណាដែលបាត់ ឬដុះមិនល្អដោយសារក្តាមកាត់ អណ្តើក ឬងាប់ដោយកត្តាផ្សេងៗទៀត ត្រូវយកសំណាបដែលរក្សាទុកនោះមកស្ទូងជួសឡើងវិញ។

### ៣.៧. ការកម្ចាត់ពូជលាយ និងស្មៅ

- **ការកម្ចាត់ពូជលាយ:** នៅក្នុងផលិតកម្មគ្រាប់ពូជចាំបាច់ត្រូវសម្អាតពូជលាយ និងកម្ចាត់ស្មៅឱ្យបានស្អាតល្អដើម្បីទទួលបានគ្រាប់ពូជមានគុណភាពល្អស្របតាមស្តង់ដារ។

ការកម្ចាត់ពូជលាយត្រូវធ្វើឡើង៣លើក៖

- **លើកទី១៖** ត្រូវនៅក្នុងដំណាក់កាលស្រូវបែកគុម្ព ពោលគឺ ២-៣ សប្តាហ៍ក្រោយស្ទូងដោយបើវិធីសាស្ត្រដកដោយដៃ តាមរយៈការសង្កេតមើលលើពណ៌ស្លឹក និងមុំស្លឹក។




រូបភាពទី៧៖ការដកពូជលាយ និងស្មៅក្នុងស្រែផលិតកម្មគ្រាប់ពូជស្រូវ នៅដំណាក់កាលបែកគុម្ព

- **លើកទី២៖** ត្រូវធ្វើឡើងក្នុងដំណាក់កាលចេញផ្កាដំបូង រហូតដល់ដំណាក់កាលដាក់ទឹកដោះតាមរយៈការសង្កេតលើកម្ពស់ដើម ពណ៌ស្លឹក លក្ខណៈស្លឹកទង់ជ័យ ប្រវែង និងទំហំក្បួរ និងប្រវែងនឹងទំហំគ្រាប់នៃពូជលាយដោយប្រើវិធីសាស្ត្រដកដោយ

ដៃ។





រូបភាពទី៨៖ ការដកពូជលាយ និងស្មៅក្នុងស្រែផលិតកម្មគ្រាប់ពូជស្រូវដំណាក់កាលផ្កា

**លើកទី៣៖** ត្រូវធ្វើឡើង២សប្តាហ៍មុនពេលប្រមូលផល តាមរយៈការសង្កេតមើលប្រវែង ទំហំ និងពណ៌របស់ក្បួរនៃពូជលាយ ដោយប្រើវិធីសាស្ត្រកាត់ដោយដៃ។






រូបភាពទី៩៖ ការដកពូជលាយ និងស្មៅក្នុងស្រែផលិតកម្មគ្រាប់ពូជស្រូវនៅដំណាក់កាលទុំ

ដើម ឬគុម្ពស្រូវពូជលាយ ដែលទទួលបានពីសកម្មភាពទាំង៣លើកខាងលើនោះ ត្រូវប្រមូលដាក់មួយដុំ ហើយយកចេញពីស្រែផលិតពូជ ឬធ្វើជាចំណីសត្វ។

**ការកម្ចាត់ស្មៅ៖** ស្មៅដែលមានសន្លឹកតូច ធំ និងកក់ ប៉ះពាល់ដល់ការលូតលាស់របស់ដំណាំស្រូវតាមរយៈការប្រជែងគ្នាយកពន្លឺព្រះអាទិត្យ និងការស្រូបយកសារជាតិចិញ្ចឹម ហើយជាជម្រកដល់សត្វល្អិតចង្រៃថែមទៀតផង។ ការកម្ចាត់ស្មៅត្រូវធ្វើឡើងជាប្រចាំយ៉ាងពិសេសនៅក្នុងដំណាក់កាលលូតលាស់របស់ដំណាំស្រូវ និងត្រូវធ្វើដំណាលគ្នានឹងការកម្ចាត់ពូជលាយផងដែរ។ ការកម្ចាត់ស្មៅអាចធ្វើឡើងបានតាមរយៈ

ដៃ។




រូបភាពទី៨៖ ការដកពូជលាយ និងស្មៅក្នុងស្រែផលិតកម្មគ្រាប់ពូជស្រូវដំណាក់កាលផ្កា

លើកទី៣៖ ត្រូវធ្វើឡើង២សប្តាហ៍មុនពេលប្រមូលផល តាមរយៈការសង្កេតមើលប្រវែង ទំហំ និងពណ៌របស់កួរនៃពូជលាយ ដោយប្រើវិធីសាស្ត្រកាត់ដោយដៃ។




រូបភាពទី៩៖ ការដកពូជលាយ និងស្មៅក្នុងស្រែផលិតកម្មគ្រាប់ពូជស្រូវនៅដំណាក់កាលទុំ

ដើម ឬគុម្ពស្រូវពូជលាយ ដែលទទួលបានពីសកម្មភាពទាំង៣លើកខាងលើនោះ ត្រូវប្រមូលដាក់មួយដុំ ហើយយកចេញពីស្រែផលិតពូជ ឬធ្វើជាចំណីសត្វ។

ការកម្ចាត់ស្មៅ៖ ស្មៅដែលមានសន្លឹកតូច ធំ និងកក់ ប៉ះពាល់ដល់ការលូតលាស់របស់ដំណាំស្រូវតាមរយៈការប្រជែងគ្នាយកពន្លឺព្រះអាទិត្យ និងការស្រូបយកសារជាតិចិញ្ចឹម ហើយជាជម្រកដល់សត្វល្អិតចង្រៃថែមទៀតផង។ ការកម្ចាត់ស្មៅត្រូវធ្វើឡើងជាប្រចាំយ៉ាងពិសេសនៅក្នុងដំណាក់កាលលូតលាស់របស់ដំណាំស្រូវ និងត្រូវធ្វើដំណាលគ្នានឹងការកម្ចាត់ពូជលាយផងដែរ។ ការកម្ចាត់ស្មៅអាចធ្វើឡើងបានតាមរយៈ

- ការពង្រាប និងភ្ជួរដីយ៉ាងតិចពីរដង
- ការដាំដុះតាមរបៀបជាជួរ
- ការកែសម្រួលកម្ពស់ទឹកនៅក្នុងស្រែ។

ការកម្ចាត់ស្មៅអាចធ្វើឡើងដោយដៃ ឬដោយថ្នាំគីមី។ ថ្នាំបាញ់ស្មៅអាចប្រើប្រាស់ទៅបានតែក្នុងកម្រិតមួយដែលការរាលដាលមិនអាចគ្រប់គ្រងបានដោយប្រើប្រាស់វិធានការខាងលើ។ ក៏ប៉ុន្តែ ជាទូទៅការប្រើថ្នាំគីមីមិនត្រូវបានផ្តល់អនុសាសន៍ប្រើប្រាស់នៅក្នុងវាលស្រែផលិតគ្រាប់ពូជឡើយ។

**សម្គាល់៖**

- អ្នកបោចស្មៅត្រូវស្គាល់ដើមស្មៅ និងដើមស្រូវឱ្យច្បាស់ថា ដើមស្រូវមានអណ្តាតស្លឹក១ និងត្រចៀកស្លឹក២ ចំពោះស្មៅវិញខ្លះមានខ្លះអត់មានអណ្តាតស្លឹក ហើយស្មៅគ្មានត្រចៀកស្លឹកទេ។
- ការកម្ចាត់ស្មៅត្រូវធ្វើឡើងមុនពេលបាចជី ៣-៤ ថ្ងៃជាការត្រឹមត្រូវ។




រូបភាពទី១០៖លក្ខណៈខុសគ្នារវាងដើមស្រូវ និងស្មៅ

### ៣.៨ ការគ្រប់គ្រងទឹក

ទឹក គឺជាកត្តាសំខាន់មួយដែលមានឥទ្ធិពលទៅលើការផលិតគ្រាប់ពូជស្រូវ។ តម្រូវការទឹករបស់ដំណាំស្រូវ គឺអាស្រ័យទៅតាមដំណាក់កាលនៃការលូតលាស់របស់វា និងលក្ខខណ្ឌអាកាសធាតុ។ ការគ្រប់គ្រងទឹកក្នុងវាលស្រែផលិតកម្មគ្រាប់ពូជស្រូវសមស្របសម្រាប់ ការលូតលាស់ល្អរបស់ដំណាំស្រូវត្រូវគោរពតាមចំណុចដូចខាង

ក្រោម៖

- ត្រូវរក្សាកម្ពស់ទឹកសមស្របក្នុងស្រែអាស្រ័យតាមរដូវនីមួយៗគឺ៖
    - ស្រូវរដូវប្រាំងកម្ពស់ ១-៥ ស.ម
    - ស្រូវរដូវវស្សាកម្ពស់ ៥-១០ ស.ម។

ត្រូវចង់ចាំថា៖ ទឹកក្នុងស្រែជួយកម្ចាត់សត្វល្អិតចង្រៃ និងស្មៅផងដែរ។

- ត្រូវតែមានភ្លឺគ្រប់គ្រាន់ព័ន្ធជុំវិញសម្រាប់ការគ្រប់គ្រងទឹកឱ្យបានល្អសម្រាប់ស្រែផលិតគ្រាប់ពូជស្រូវនីមួយៗ

- ត្រូវបង្ហូរទឹកចេញពីស្រែ ១០-១៥ថ្ងៃ មុនពេលប្រមូលផលចាប់ផ្ដើម។

ប្រសិទ្ធភាពនៃការគ្រប់គ្រងទឹកគឺ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការពង្រាបដី។ ការពង្រាបដីជួយរក្សាជម្រៅទឹកក្នុងស្រែស្មើៗគ្នា និងការស្រូបយកសារធាតុចិញ្ចឹមដោយដំណាំស្រូវបានស្មើៗគ្នាល្អ។ ប្រសិនបើអាចធ្វើបាន អ្នកផលិតគ្រាប់ពូជស្រូវគួរធ្វើការពង្រាបដីក្នុងរយៈពេលប្រាំឆ្នាំម្តង។ ការពង្រាបដីអាចធ្វើឡើងទៅបានតាមរយៈការភ្ជួររាស់ កៀរ ឬការពង្រាបដីដោយឧបករណ៍ប្រើកាំរស្មីឡាស៊ែរ។

### ៣.៩ ការគ្រប់គ្រងជាតិដី

ការថែទាំជីជាតិដីបានល្អមានសារសំខាន់សម្រាប់ការដាំដុះដំណាំ ជាពិសេសការផលិតគ្រាប់ពូជស្រូវ។ដើម្បីរក្សាជីជាតិក្នុងដីបានល្អ ដំណាំស្រូវដែលត្រូវបានដាំពី ១-២ ដងក្នុងមួយឆ្នាំ ត្រូវការបំពេញឡើងវិញនូវសារធាតុចិញ្ចឹម NPK និងសារធាតុចិញ្ចឹមផ្សេងទៀតដែលដំណាំស្រូវត្រូវការចាំបាច់ដើម្បីដុះលូតលាស់បានល្អ។ ការដាក់សារធាតុចិញ្ចឹម (ជី) គឺអាស្រ័យទៅលើតម្រូវការរបស់ដំណាំស្រូវ កម្រិតទឹកក្នុងស្រែ និងលក្ខខណ្ឌអាកាសធាតុ។ ដើម្បីគិតគូរពីការប្រើប្រាស់ជីបានត្រឹមត្រូវ ត្រូវសិក្សាឱ្យស្គាល់ថាតើដីស្រែនោះជាដីប្រភេទ ឬក្រុមអ្វី? ឧទាហរណ៍៖ក្រុមប្រទះឡាង បាកាន ឬក្បាលពោធិ៍ ជាដើម)។ ការស្គាល់ប្រភេទក្រុមដីអាចឱ្យយើងគណនាកម្រិតនៃការប្រើប្រាស់ជីបានត្រឹមត្រូវ ឆ្លើយតបទៅនឹងតម្រូវការតាមប្រភេទ និងបរិមាណជីដែលប្រើប្រាស់លើដំណាំស្រូវ។

ប្រភេទក្រុមដីស្រែផលិតគ្រាប់ពូជស្រូវមួយចំនួន ដែលបានណែនាំបរិមាណប្រើ

ប្រាស់ជីក្នុង១ ហ.ត មានដូចខាងក្រោម៖

- ក្រុមដីប្រទះឡាង កម្រិតប្រើ៖ N 40-60, P 23-29, K 20-30
    - ជី UREA ៖ ៤០-៨៧,៥ គ.ក្រ
        - ទ្រាប់បាត៖ ២០%
        - បំប៉នទី១៖ ៣០%
        - បំប៉នទី២៖ ៥០%
- ជី DAP ៖ ៥០-៨៨ គ.ក្រ
    - ទ្រាប់បាត៖ ១០០%
- ជីប៉ូតាស្យូម KCL ៖ ៥០ គ.ក្រ
    - ទ្រាប់បាត៖ ១០០%
- ជីធម្មជាតិ ៖ លាមកសត្វ ឬ ជីកំប៉ុស្ត ៣.០០០-៥.០០០ គ.ក្រ
    - ទ្រាប់បាត៖ ១០០%
- ក្រុមដីបាកាន កម្រិតប្រើ៖ N 30-70, P 20-30, K 0-15
- ជី UREA ៖ ១១៣-១៣៨ គ.ក្រ
    - ទ្រាប់បាត៖ ២០%
    - បំប៉នទី១៖ ៣០%
    - បំប៉នទី២៖ ៥០%
- ជី DAP ៖ ៤៣-៦៥ គ.ក្រ
    - ទ្រាប់បាត៖ ១០០%
- ជីប៉ូតាស្យូម KCL ៖ ២៥ គ.ក្រ
    - ទ្រាប់បាត៖ ១០០%
- ជីធម្មជាតិ ៖ លាមកសត្វ ឬ ជីកំប៉ុស្ត ៣.០០០-៥.០០០ គ.ក្រ
- ក្រុមដីក្បាលពោធិ៍ រូបមន្តប្រើ៖ N 66-120, P 23-34, K 0
- ជី UREA ៖ ១២៥-៣០០ គ.ក្រ

- ទ្រាប់បាត៖ ២០%
- បំប៉នទី១៖ ៣០%
- បំប៉នទី២៖ ៥០%

- ជី DAP ៖ ៥០ គ.ក្រ
  - ទ្រាប់បាត៖ ១០០%
- ជីធម្មជាតិ ៖ លាមកសត្វ ឬ ជីកំប៉ុស្ត ៣.០០០-៥.០០០ គ.ក្រ
  - ទ្រាប់បាត៖ ១០០%

**សម្គាល់:**

- ទ្រាប់បាត មានន័យថា ការដាក់ជីមុនរាស់ ឬភ្ជួរចុងក្រោយ
- បំប៉នទី១ មានន័យថា ការបាចជី ១០-១៥ ថ្ងៃក្រោយស្ទូង
- បំប៉នទី២ មានន័យថា ការបាចជីនៅពេល៣ ទៅ ៥ ថ្ងៃមុនដំណាក់កាលកំណរក្ួរ
- ចំពោះស្រែប្រាំង ជី UREA អាចប្រើទ្រាប់បាត ៥០% និង ៥០% ទៀតនៅពេល ៣-៥ ថ្ងៃមុនដំណាក់កាលកំណរក្ួរ
- កម្ពស់ទឹកសមស្របសម្រាប់ការបាចជីគឺ ៥ -១៥ ស.ម
- បើស្រែគ្មានទឹកគឺមិនត្រូវបាចជីនោះទេ។

ត្រូវរក្សាជីជាតិដីរៀងរាល់ឆ្នាំដើម្បីបង្កើនផលិតកម្មគ្រាប់ពូជស្រូវក្នុងកម្រិតអតិបរមា។ ដើម្បីកែលម្អជីជាតិដី និង ចៀសវាងការខូចដី គួរប្រើប្រាស់ជីជធម្មជាតិដូចជា៖ លាមកគោ ជីកំប៉ុស្ត និងជីស្រស់ ដោយកាត់បន្ថយការប្រើប្រាស់ជីគីមី។

### ៣.១០. ការគ្រប់គ្រងសត្វល្អិតចង្រៃ និងជំងឺ

សត្វល្អិតចង្រៃ និងជំងឺបំផ្លាញដល់ដំណាំស្រូវដែលធ្វើបាត់បង់ទិន្នផលដំណាំ និងផលិតកម្មធ្លាក់ចុះ។ វិធានការគ្រប់គ្រងដែលអនុវត្តចំពោះសត្វល្អិតចង្រៃ និងជំងឺអាចមានភាពខុសៗគ្នាអាស្រ័យលើកកម្រិតនៃការបំផ្លាញ ឬខូចខាត។

ការគ្រប់គ្រងសត្វល្អិតចង្រៃ៖ សត្វល្អិតភាគច្រើនដែលវាយប្រហារមកលើដំណាំ

ស្រូវគឺៈ ទ្រីប មមាចត្នោត ដង្កូវបំពង់កាត់ស្លឹក ដង្កូវស៊ីរូងដើម ដង្កូវមូរស្លឹក ចៃខ្មៅ។ល។ សត្វចង្រៃដែលបំផ្លាញមកលើដំណាំស្រូវរួមមានៈ ខ្យង កណ្ដុរ និងចាបជាដើម។ វិធានការក្នុងការគ្រប់គ្រងសម្រាប់ប្រភេទសត្វល្អិត និងសត្វចង្រៃនីមួយៗគឺខុសគ្នា។ អ្នកផលិតគ្រាប់ស្រូវពូជត្រូវគោរពតាមសេចក្ដីណែនាំដែលមានសរសេរនៅក្នុងសៀវភៅ "សត្វល្អិតចង្រៃកើតលើដំណាំសំខាន់នៅកម្ពុជា" ឬសៀវភៅបង្កុំបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវ ដែលត្រូវបានរៀបចំ និងបោះពុម្ពផ្សាយដោយនាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម។

ការគ្រប់គ្រងជំងឺៈ ជំងឺចម្បងដែលវាតត្បាតមកលើដំណាំស្រូវមានដូចជាៈ អុជត្នោត ជំងឺរលួយស្រទបស្លឹក រលាកស្រទបស្លឹក។ល។ អ្នកផលិតគ្រាប់ពូជស្រូវត្រូវគោរពតាមសេចក្ដីណែនាំដែលមានសរសេរនៅក្នុង"សត្វល្អិតចង្រៃកើតលើដំណាំសំខាន់នៅកម្ពុជា" និងសៀវភៅបង្កុំបច្ចេកទេសប្រពលវប្បកម្មដំណាំស្រូវដែលរៀបចំដោយនាយកដ្ឋានដំណាំស្រូវ នៃអគ្គនាយកដ្ឋានកសិកម្ម។

### ៣.១១ ការងារប្រមូលផល

ការប្រមូលផលស្រូវបានត្រឹមត្រូវមិនត្រឹមតែមានសារសំខាន់ដើម្បីទទួលបានគ្រាប់ពូជស្រូវមានគុណភាពខ្ពស់ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងកាត់បន្ថយការខាតបង់បរិមាណគ្រាប់ពូជក្នុងអំឡុងពេលប្រតិបត្តិការប្រមូលផលនោះផងដែរ។ ផ្អែកលើបទពិសោធន៍នានាក្នុងការប្រមូលផលស្រូវ ត្រូវអនុវត្តតាមរបៀប និងចំណុចសំខាន់ៗដូចខាងក្រោមៈ

#### ៣.១១.១. ការច្រូតកាត់ដោយដៃ ឬម៉ាស៊ីនច្រូតពាក់កណ្ដាលស្វ័យប្រវត្តិ

ការច្រូតកាត់ដោយដៃ ឬម៉ាស៊ីនច្រូតពាក់កណ្ដាលស្វ័យប្រវត្តិដែលទទួលបានលទ្ធផលល្អ ទាំងគុណភាព និងបរិមាណ ត្រូវគោរពតាមចំណុចមួយចំនួនដូចខាងក្រោមៈ

- ត្រូវច្រូតស្រូវនៅពេលដែលគ្រាប់ស្រូវទុំ ប្រហែល ៨៥-៩០% ដោយគិតពីផ្នែកចុងនៃកួរស្រូវ
- មិនត្រូវច្រូតស្រូវដែលគ្រាប់មិនទាន់ទុំ ឬទុំជ្រុលឡើយ(ទុំញួស) ពីព្រោះវា

បណ្តាលឱ្យមានការជ្រុះគ្រាប់ច្រើន និងប្រេះស្រាំគ្រាប់

- សំណើមគ្រាប់សមស្របសម្រាប់ធ្វើការច្រូតកាត់គឺ ១៧-២០%
- ដើម្បីរក្សាគុណភាព និងភាពសុទ្ធរបស់គ្រាប់ពូជស្រូវ មិនត្រូវច្រូតស្រូវក្នុងចម្ងាយ១ម៉ែត្រពីព្រំ ឬភ្លឺឡើយ។ ផ្នែកនេះអាចច្រូតតាមក្រោយ និងទុកដាក់ដោយឡែកដើម្បីលក់ជាស្រូវចំណី
- ត្រូវហាលកណ្តាប់ស្រូវលើវាលស្រែឱ្យបានស្តើង ចៀសវាងការគរជាគំនរក្នុងរយៈពេលយូរធ្វើឱ្យមានការកើនឡើងនៃកម្តៅ បណ្តាលឱ្យប៉ះពាល់ដល់គុណភាពគ្រាប់ពូជ
- ត្រូវប្រើសំបកវេចខ្ចប់គ្រាប់ពូជស្រូវពីទីវាល ដោយប្រើពណ៌ផ្សេងៗគ្នាទៅតាមចំណាក់ថ្នាក់នៃពូជស្រូវនីមួយៗ ចៀសវាងការច្រឡំគ្នា
- មិនត្រូវឱ្យគ្រាប់ពូជស្រូវដែលច្រូតកាត់រួចទទឹកទឹកវិញនោះទេ។ គ្រាប់ពូជស្រូវដែលច្រូតកាត់រួចត្រូវគ្របការពារឱ្យបានត្រឹមត្រូវពីការទទឹកទឹក
- មិនត្រូវទុកឱ្យគ្រាប់ពូជស្រូវ ដែលច្រូតកាត់រួចស្ថិតក្រោមកម្តៅថ្ងៃខ្លាំងពេកនោះទេ។





រូបភាពទី១១៖ ការប្រមូលគ្រាប់ពូជស្រូវបន្ទាប់ពីច្រូតរួច

### ៣.១១.២ ការច្រូតដោយម៉ាស៊ីនទំនើប

ក្នុងករណីប្រើប្រាស់ម៉ាស៊ីនទំនើបក៏ត្រូវការ កាសម្អាតឱ្យបានស្អាតល្អ មុនដំណើរការច្រូតកាត់ដែរ។ ចៀសវាងការលាយឡំជាមួយនឹងគ្រាប់ស្រូវផ្សេងៗទៀតដែលនៅ

សេសសល់ជាប់ក្នុងម៉ាស៊ីនតាមរយៈការច្រូតកាត់កាលពីពេលមុន។ គួរប្រើប្រាស់ម៉ាស៊ីនច្រូតសម្រាប់ច្រូតតែប្រភេទពូជស្រូវតែមួយ។ វិធីច្រូតកាត់ដោយប្រើប្រាស់ម៉ាស៊ីនទំនើបបែបនេះមានការពេញនិយមណាស់ក្នុងពេលបច្ចុប្បន្ន។ ប៉ុន្តែ វាមានគុណសម្បត្តិ និងគុណវិបត្តិដូចខាងក្រោម៖

- **គុណសម្បត្តិ៖**
  - ច្រូតលឿន ឆាប់រួច
  - មិនចាំបាច់មានសកម្មភាពហាលដៃ បោក ក្រោយច្រូតនោះទេ
  - ចំណាយសោហ៊ុយតិចជាងការច្រូតដោយដៃ
  - គ្រាប់ពូជមិនទុករង់ចាំយូរនៅក្នុងស្រែ មិនខូចគុណភាពគ្រាប់
  - មិនត្រូវការកម្លាំងមនុស្សច្រើន។
- **គុណវិបត្តិ៖**
  - លំបាកច្រូត ឬច្រូតមិនកើតចំពោះស្រែតូចៗ
  - ត្រូវការបច្ចេកទេសត្រួតពិនិត្យម៉ាស៊ីនខ្ពស់(ត្រូវការអ្នកបច្ចេកទេសម៉ាស៊ីន)
  - ច្រូតមិនបានចំពោះស្រែដែលមានទឹក ឬភក់ច្រើនពេក
  - ច្រូតមិនបានល្អ និងបាត់គ្រាប់ពូជច្រើនចំពោះដើមស្រូវដួលច្រើនក្នុងស្រែ។

ករណីច្រូតដោយម៉ាស៊ីនទំនើប គ្រាប់ពូជស្រូវត្រូវដឹកពីវាលស្រែភ្លាមៗទៅកន្លែងកែច្នៃ។ ដូច្នេះ តម្រូវឱ្យការរៀបចំស៊ីសង្វាក់គ្នារវាងការងារទីវាល និងការងារកែច្នៃ ជាពិសេសការរៀបចំ ការហាលសម្ងួត លៃលកយ៉ាងណាចៀសវាងការគរគ្រាប់ពូជទុកក្នុងរយៈពេលយូរនៅកន្លែងកែច្នៃ។

### ៣.១២. ប្រតិបត្តិការក្រោយការច្រូតកាត់ និងការកែច្នៃគ្រាប់ពូជ(នៅមជ្ឈមណ្ឌលកែច្នៃគ្រាប់ពូជ)

#### ៣.១២.១.ការបោកស្រូវ

សម្រាប់ដំណាំស្រូវដែលច្រូតកាត់រួច ការបោកស្រូវគួរធ្វើឡើងភ្លាមៗបន្ទាប់ពីការច្រូត។ ដើម្បីរក្សាការលាយឡំនៃគ្រាប់ពូជ ទីកន្លែងបោក និងប្រដាប់បោកត្រូវតែសម្អាតឱ្យបានត្រឹមត្រូវមុនពេលបោក។ ការបោកមាន២របៀបគឺ ដោយដៃ និងដោយ

ម៉ាស៊ីន។

ការបោកដោយដៃ៖ ការបោកស្រូវអាចធ្វើដោយដៃដោយប្រើក្តារបោក។





*រូបភាពទី១២៖ ការបោកដោយដៃ*

ករណីនេះ ត្រូវការប្រើកម្លាំងមនុស្សច្រើនសម្រាប់ការកង ឬប្រមូលកណ្តាប់ ឬដៃ កម្លាំងពលកម្មបោក និងពេលវេលាច្រើន។ ប៉ុន្តែការបោកដោយដៃពុំសូវមានការប៉ះពាល់ដល់ការបាក់បែកដល់គ្រាប់ពូជស្រូវនោះទេ។ ការបោកប្រភេទនេះច្រើនអនុវត្តចំពោះកសិករផលិតស្រូវចំណី ឬស្រូវពូជទ្រង់ទ្រាយទ្រាយតូចតាចប៉ុណ្ណោះ។

ការបោកដោយម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ៖ ការបោកដោយម៉ាស៊ីនបោកស្រូវពាក់កណ្តាលស្វ័យប្រវត្តិនេះគួរអនុវត្តតាមចំណុចដូចខាងក្រោម៖

- ត្រូវប្រមូលកណ្តាប់ស្រូវគរជាគំនរធំៗនៅទីតាំងដែលម៉ាស៊ីនបោកអាចចូលទៅបាន និងដំណើរការបោកបាន
- ត្រូវត្រួតពិនិត្យម៉ាស៊ីនបោក បោសសម្អាតម៉ាស៊ីនឱ្យបានស្អាត មុនដំណើរការបោក
- ត្រៀមលក្ខណ: កម្លាំងពលកម្ម និងសម្ភារសម្រាប់ដំណើរការបោកឱ្យបានរលូន ដូចជា៖ ល្អី ប៉ោត សម្បកវេចខ្ចប់ ខ្សែចង ។ល។
- ត្រូវពិនិត្យគុណភាពបោក ដូចជា៖ ភាពស្អាត ការបាក់បែកគ្រាប់ការបាត់បង់គ្រាប់ពូជដោយសារលាយទៅជាមួយចំបើងជាដើម

- ប្រសិនជាមិនទាន់ត្រឹមត្រូវលើករណីណាមួយ ត្រូវកែតម្រូវម៉ាស៊ីនបោកឡើងវិញ។

### ៣.១២.២. ការដឹកជញ្ជូន

គ្រាប់ពូជស្រូវដែលច្រូតកាត់បោកបែនរួចត្រូវវេចខ្ចប់ដឹកជញ្ជូនទៅកាន់ទីកន្លែងកែច្នៃគ្រាប់ពូជស្រូវឱ្យបានឆាប់។ អំឡុងពេលដឹកជញ្ជូនត្រូវអនុវត្តតាមចំណុចដូចខាងក្រោម៖

- ត្រូវពិនិត្យមើលស្ថានភាពបាវឱ្យបានសមស្របមុនពេលវេចខ្ចប់គ្រាប់ពូជ។ ប្រសិនបាវរហែក ឬខូចចូរប្តូរបាវថ្មី ចៀសវាងការលេចធ្លាយគ្រាប់ពូជច្របូកច្របល់ជាមួយនឹងគ្រាប់ពូជស្រូវផ្សេងទៀត
- មិនត្រូវដឹកជញ្ជូនគ្រាប់ពូជស្រូវមួយប្រភេទជាមួយនឹងគ្រាប់ពូជស្រូវប្រភេទផ្សេងទៀត ឬវត្ថុនានាដែលអាចងាយលាយឡំ ឬឆាបឆេះនោះឡើយ
- ត្រូវលាងបោសសម្អាតឱ្យបានស្អាត មុនពេលប្រើប្រាស់មធ្យោបាយសម្រាប់ដឹកជញ្ជូនគ្រាប់ពូជស្រូវ
- អ្នកដឹកត្រូវទទួលខុសត្រូវក្នុងការថែរក្សាគុណភាព និងបរិមាណគ្រាប់ពូជស្រូវពីទីវាលរហូតដល់ឃ្លាំងទើបប្រគល់ឱ្យនាយឃ្លាំង។ ពេលប្រគល់ទទួលគ្រាប់ពូជស្រូវ នាយឃ្លាំងត្រូវផ្ទៀងផ្ទាត់ទំនិញជាក់ស្តែងនឹងតួលេខក្នុងឯកសារពីទីវាល។

ក្រោយច្រូតកាត់រួច គ្រាប់ពូជត្រូវធ្វើការហាល សម្ងួត និងសម្ងួត ដោយធ្វើឡើងនៅមុនពេលទុកដាក់ក្នុងឃ្លាំង។ ប្រតិបត្តិការទាំងនេះ ត្រូវធ្វើដោយប្រុងប្រយ័ត្នដើម្បីធានានូវភាពសុទ្ធ និងគុណភាពរបស់គ្រាប់ពូជស្រូវ។

### ៣.១៣.៣. ការសម្ងួត

កម្រិតសំណើមរបស់គ្រាប់ពូជស្រូវមានឥទ្ធិពលទាំងគុណភាពគ្រាប់ពូជ និងពេលវេលានៃការទុកដាក់។កម្រិតសំណើមគ្រាប់ពូជទាបគឺសក្តិសមបំផុតក្នុងការរក្សាគ្រាប់ពូជក្នុងលក្ខខណ្ឌល្អ ហើយអាចទុកដាក់បានរយៈពេលវែងថែមទៀត។ ជាធម្មតាគ្រាប់ពូជស្រូវគួរទុកក្នុងកម្រិតសំណើមចន្លោះពី ១២% ទៅ ១៤% អាស្រ័យទៅតាម

ចំណាត់ថ្នាក់គ្រាប់ពូជ។ គ្រាប់ពូជស្រូវចាំបាច់ត្រូវសម្ងួតឱ្យបានត្រឹមត្រូវ និងយកចិត្តទុកដាក់ដើម្បីរក្សាគុណភាព។

ការសម្ងួតគ្រាប់ពូជមានពីររបៀបគឺៈ ការសម្ងួតដោយកម្តៅថ្ងៃ និងការប្រើប្រាស់ឡសម្ងួតគ្រាប់ពូជ។

- ការសម្ងួតដោយកម្តៅថ្ងៃៈ ការសម្ងួតដោយកម្តៅថ្ងៃត្រូវបានអនុវត្តប្រសិនបើមានពន្លឺថ្ងៃគ្រប់គ្រាន់ និងកម្លាំងពលកម្ម ឬកម្មករច្រើនអាចដំណើរការបាន។ ខាងក្រោមនេះជាចំណុចសំខាន់ៗដែលត្រូវអនុវត្តៈ
- មិនត្រូវទុកគ្រាប់ពូជជាគំនរក្នុងរយៈពេលយូរ ដោយពុំបានចាក់ចេញពីបាវនោះទេ

ឧទាហរណ៍ៈសំណើមគ្រាប់ស្រូវ ១៨% មិនអនុញ្ញាតឱ្យទុកលើសពី ៣៦ ម៉ោងនោះឡើយ

- ត្រូវចាក់គ្រាប់ពូជស្រូវជាធារក្នុងឃ្លាំងកម្រាសប្រហែល ១០ ស.ម ហើយចាំបាច់ត្រូវកូរ ឬវិវារាល់ ១-២ ម៉ោងម្តង ប្រសិនបើមានការខ្វះខាតមធ្យោបាយសម្ងួត
- ត្រូវប្រើកន្ទេល ឬតង់ទំហំ ២ x ៣ ម ដែលសម្អាតស្អាត មិនរហែកសម្រាប់ការហាលគ្រាប់ពូជស្រូវ
- ត្រូវពង្រាយគ្រាប់ពូជនៅលើកម្រាលតង់ក្នុងកម្រាស់គ្រាប់ស្រូវ ២-៣ ស.ម ឬចាក់២បាវ(៥០គ.ក្រ) លើតង់នីមួយៗ
- ត្រូវជ្រោយត្រលប់គ្រាប់ពូជស្រូវ រៀងរាល់ ១ ម៉ោងម្តង នៅចន្លោះម៉ោង ៧-១១ ព្រឹក និងកន្លះម៉ោងម្តងនៅចន្លោះពីម៉ោង ១១-៤ រសៀល។ ការអនុវត្តបែបនេះគឺចំពោះកម្តៅថ្ងៃគ្រប់គ្រាន់(៤០-៥០ អង្សាសេ)
- ត្រូវវាស់សំណើមគ្រាប់ពូជដែលកំពុងហាលរៀងរាល់១ម៉ោងម្តង។ត្រូវយកសំណាកទុកក្នុងម្លប់ឱ្យត្រជាក់ប្រហែល ១៥ នាទីទើបវាស់
- មិនត្រូវឱ្យគ្រាប់ពូជស្រូវមានកម្តៅពេលសម្ងួតលើសពី ៤២ អង្សាសេទេ
- មិនត្រូវអនុវត្តល្បឿនសម្ងួតគ្រាប់ពូជស្រូវលើសពី ១,៥%ក្នុង១ម៉ោងឡើយ

ករណីគ្រាប់សើមខ្លាំង (លើសពី ២០%) ប្រើល្បឿនសម្ងួតលឿន តែបើសំណើមគ្រាប់ទាបត្រូវប្រើល្បឿនសម្ងួតយឺត។ ការប្រើល្បឿនសម្ងួតលើសពី ១,៥% ក្នុង១ម៉ោង បណ្តាលឱ្យគ្រាប់ពូជប្រេះស្រាំ និងខូចគុណភាព។

- ត្រូវកំណត់យកសំណើមគ្រាប់ពូជសម្រេចស្ថិតនៅចន្លោះពី ១២%-១៤% អាស្រ័យទៅនឹងចំណាត់ថ្នាក់នៃគ្រាប់ពូជ
- ត្រូវប្រមូលគ្រាប់ពូជស្រូវទុកដាក់នៅពេលរសៀលជាការចាំបាច់។



*រូបភាពទី១៣៖ ការសម្ងួតគ្រាប់ពូជស្រូវក្រោមពន្លឺថ្ងៃ*

- ការសម្ងួតគ្រាប់ពូជស្រូវដោយឡសម្ងួតសំប៉ែត( Flat bed dryer )៖

ឡសម្ងួតគ្រាប់ពូជមានភាពចាំបាច់ណាស់សម្រាប់សម្ងួតគ្រាប់ពូជ ជាពិសេសអំឡុងពេលរដូវវស្សាក្នុងស្ថានភាពមេឃមានពពកច្រើន(គ្មានពន្លឺថ្ងៃ)។ ឡសម្ងួតគ្រាប់ពូជដោយប្រើម៉ាស៊ីនមានតម្លៃថ្លៃ ហើយតម្រូវឱ្យមានប្រតិបត្តិករដែលមានជំនាញខ្ពស់ថែមទៀត។ ចំណែកឯឡសម្ងួតសំប៉ែតមានភាពងាយស្រួលក្នុងការប្រើ និង សមរម្យសម្រាប់ស្ថានភាពនៅជនបទ។ ប៉ុន្តែ ឡសម្ងួតសំប៉ែតនេះត្រូវប្រើប្រាស់ដោយមានការប្រុងប្រយ័ត្ន ជាពិសេសនៅពេលដាក់គ្រាប់ពូជស្រូវចូលឡ និងគ្រប់គ្រងសីតុណ្ហភាពនៅពេលសម្ងួត។ ការសម្ងួតដោយឡសម្ងួតត្រូវគោរពតាមគោលការណ៍បច្ចេកទេសមួយចំនួនដូចខាងក្រោម៖

- ត្រូវវាស់សំណើមគ្រាប់រៀងរាល់១ម៉ោងម្តងក្នុងពេលសម្ងួត
- ត្រូវជ្រោយ ឬកូរត្រឡប់គ្រាប់ពូជពីផ្នែកក្រោមឡើងទៅលើ ពីផ្នែកលើទៅ

ក្រោមវិញ រៀងរាល់ ៥-៦ ម៉ោងម្តង ធ្វើយ៉ាងនេះដើម្បីផ្លាស់ប្តូរកម្តៅ និងគ្រាប់ពូជស្រូវទទួលបានកម្តៅ និងបំភាយសំណើមស្មើគ្នាល្អ

- ធ្វើយ៉ាងណាជៀសវាងការដើរជាន់ច្រើនសារលើគ្រាប់ស្រូវក្នុងផ្ទៃឡ បណ្តាលឱ្យហាប់គ្រាប់ពូជ និងប៉ះពាល់ដល់គុណភាពសម្ងួត

- ត្រូវប្រើរយៈពេលសម្ងួតជាមធ្យម ១២-១៦ ម៉ោង អាស្រ័យតាមសំណើមគ្រាប់ពូជស្រូវមកពីទីវាល

- ត្រូវបើកល្បឿនខ្យល់ខ្លាំងបន្តិច តែកម្តៅពុំចាំបាច់ខ្ពស់ពេកទេនៅពេលចាប់ផ្តើមដំបូងដើម្បីបង្កើនល្បឿនសម្ងួតក្នុងករណីសំណើមគ្រាប់ពូជស្រូវខ្ពស់ជាង ២០% ហើយរយៈពេល ៣-៤ ម៉ោងក្រោយមកទើបតម្លើងកម្តៅបន្ថែម

- ត្រូវយកសំណាកទុក ១៥ នាទី ឱ្យត្រជាក់មុនពេលវាស់សំណើម

- ត្រូវគោរពតាមការណែនាំបច្ចេកទេសការប្រើប្រាស់ឡ។




*រូបភាពទី១៤៖ ការសម្ងួតគ្រាប់ពូជដោយប្រើឡផ្ទៃរាបស្មើ*

### ការសម្ងួតគ្រាប់ពូជស្រូវដោយឡសម្ងួតទំនើបស្វ័យប្រវត្តិ៖

ការសម្ងួតគ្រាប់ពូជស្រូវដែលមានលក្ខណៈទំនើប និងមានគុណភាពខ្ពស់ជាងគេ គឺឡសម្ងួតទំនើបស្វ័យប្រវត្តិ ដែលបច្ចុប្បន្នបណ្តារប្រទេសជឿនលឿនបានប្រើប្រាស់ក្នុងផលិតកកម្មគ្រាប់ពូជ និងផលិតកម្មស្រូវចំណីធំៗ។ ឡសម្ងួតប្រភេទនេះមានសមត្ថភាពសម្ងួតខ្ពស់ មានលក្ខណៈទំនើបក្នុងការបញ្ជាលើលក្ខខណ្ឌផ្សេងៗដូចជា៖ កម្តៅ ល្បឿនខ្យល់ ចលនាគ្រាប់ពូជ និងសំណើមគ្រាប់ពូជ ដោយឧបករណ៍ស្វ័យប្រវត្តិ។

ការសម្ងួតដោយឡសម្ងួតបែបនេះ គុណភាពនៃគ្រាប់ពូជក៏ទទួលបានកម្រិតខ្ពស់ដែរ។ ប៉ុន្តែវាមានតម្លៃខ្ពស់ និងត្រូវការចំណាយទុនច្រើន។

ក្នុងដំណើរការសម្ងួត ត្រូវត្រួតពិនិត្យការប្រែប្រួលសំណើមគ្រាប់ពូជជាប្រចាំ ដោយប្រើឧបករណ៍វាស់សំណើម។ ឧបករណ៍នេះគ្រប់គ្រងលើដំណើរការនៃការសម្ងួតគ្រាប់ពូជដើម្បីដឹងកម្រិតសំណើមរបស់គ្រាប់ពូជក្នុងកម្រិតដែលចង់បាន និងសម្រាប់ប្រើប្រាស់ក្នុងការពិនិត្យមើលកម្រិតសំណើមរបស់គ្រាប់ពូជអំឡុងពេលស្តុកទុកផងដែរ។




*រូបភាពទី១៥៖ ឧបករណ៍វាស់សំណើមគ្រាប់*

### ៣.១២.៤. ការសម្អាតគ្រាប់ពូជស្រូវ

ការសម្អាតគ្រាប់ពូជស្រូវគួរត្រូវបានធ្វើឡើងភ្លាមៗក្រោយពេល ឬនៅដំណាលគ្នានឹងការសម្ងួតដែរ។ គ្រាប់ពូជត្រូវសម្អាតដោយប្រើប្រាស់ម៉ាស៊ីនសម្អាតគ្រាប់ពូជដើម្បីដកចេញនូវគ្រាប់ខ្ទី គ្រាប់ស្កក គ្រាប់ស្មៅកម្ទេចកម្ទី គ្រាប់រុក្ខជាតិដទៃ និងវត្ថុផ្សេងទៀត ។ល។ ជាទូទៅ ការសម្អាតគ្រាប់ពូជត្រូវប្រើម៉ាស៊ីនដែលមានសមត្ថភាពខ្ពស់ដើម្បីងាយស្រួលក្នុងការកំណត់បាននូវកម្រិតដែលចង់បានតាមស្តង់ដារ។ ដំណើរការសម្អាតត្រូវមានកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- មុខពេលចាប់ផ្តើមដំណើរការសម្អាតគ្រាប់ពូជត្រូវពិនិត្យមើលម៉ាស៊ីនឱ្យបានត្រឹមត្រូវដើម្បីធានាថាម៉ាស៊ីននោះស្អាត ស្ថិតក្នុងស្ថានភាពល្អដំណើរការបាន
- ត្រូវពិនិត្យមើលល្បឿនខ្យល់ កង្ហារ កញ្ច្រែងរបស់ម៉ាស៊ីនឱ្យបានសមស្រប ពេលចាប់ផ្តើមប្រតិបត្តិការសម្អាតដើម្បីចៀសវាងគ្រាប់ពូជមិនស្អាតល្អ និងមានការ

បាត់បង់គ្រាប់ពូជល្អច្រើនដោយលាយទៅជាមួយកាកសំណល់

- ត្រូវដឹងច្បាស់ថា ពូជណា លេខឡូត៍មួយណាដែលត្រូវសម្អាត ដោយប្រើស្លាកសញ្ញាសម្គាល់ដាក់លើគំនរពូជស្រូវដែលត្រូវដំណើរការសម្អាតនោះ

- ត្រួតពិនិត្យសំបកបាវសម្រាប់ច្រកវេចខ្ចប់ និងបំពេញព័ត៌មានលើសម្បកបាវនោះឱ្យបានត្រឹមត្រូវចៀសវាសការច្រឡំពូជ និងលេខឡូត៍

- ពេលកំពុងដំណើរការសម្អាត ត្រូវយកសំណាកផលិកផលសម្រេចមកធ្វើតេស្តបរិភាគគុណភាពសម្អាតដូចជា៖ គ្រាប់ស្រូវផ្សេង គ្រាប់ពូជស្រូវអង្ករក្រហម គ្រាប់ស្មៅ កម្ទេចកម្ទី និងគ្រាប់ស្ពៀត។ កម្រិតភាពស្អាតដែលអាចយកជាការបានត្រូវផ្អែកទៅលើស្តង់ដារគុណភាពគ្រាប់ពូជទៅតាមចំណាត់ថ្នាក់នីមួយៗ។ ត្រូវប្រើវិធីសាស្ត្រក្នុងការត្រួតពិនិត្យគុណភាពពេលកំពុងសម្អាត ដូចខាងក្រោម៖

- ការធ្វើតេស្តគុណភាព

- ថ្លឹងសំណាកគ្រាប់ពូជចំនួន ៥០០ ក្រាម [A]

- រើសកម្ទេចកម្ទី រួមមាន៖ ដី ថ្ម គ្រួស បំណែកចំបើង អង្កាម ស្មៅង គ្រាប់ស្ពៀត គ្រាប់ស្រូវបាក់ តូចជាង១/២ គ្រាប់អង្ករ គ្រាប់ស្មៅ គ្រាប់ដំណាំផ្សេង និងគ្រាប់ពូជស្រូវដទៃចេញពីសំណាកគ្រាប់

- ថ្លឹងទម្ងន់កម្ទេកកម្ទីសរុប [B] / [A] x ១០០

- គណនាភាគរយគ្រាប់ពូជសុទ្ធតាមរូបមន្ត៖ គ្រាប់ពូជសុទ្ធ(%)= ១០០% - ភាគរយកម្ទេចកម្ទី

- រាប់ចំនួនគ្រាប់ស្មៅ

- រាប់ចំនួនគ្រាប់ដំណាំផ្សេង

- រាប់ចំនួនគ្រាប់ស្រូវដទៃ៖ គ្រាប់ស្រូវដទៃអាចសម្គាល់បានតាមរយៈភាពខុសគ្នានៃពណ៌ សំបកគ្រាប់ ពណ៌ចុងគ្រាប់ ទំហំគ្រាប់ និងកន្ទុយគ្រាប់។ ចំពោះស្រូវក្រហម ត្រូវបានពិនិត្យ ដោយការឆ្លុះពន្លឺភ្លើង។

- ការធ្វើតេស្តសំណើមគ្រាប់

វិធីសាស្ត្រងាយស្រួលក្នុងការកំណត់សំណើមគ្រាប់ គឺការប្រើឧបករណ៍វាស់សំណើម ប៉ុន្តែអាចមានលម្អៀងរង្វាស់ខ្លះ អាស្រ័យតាមប្រភេទឧបករណ៍។ របៀបប្រើប្រាស់ឧបករណ៍វាស់សំណើម មានដូចខាងក្រោម៖

- បើកភ្លើងឧបករណ៍
- ត្រូវធានាថា ឧបករណ៍ត្រូវមានមុខងារប្រើប្រាស់សម្រាប់ការវាស់គ្រាប់ស្រូវ
- ដាក់គ្រាប់ស្រូវនៅលើថាស ឬថានរបស់ឧបករណ៍
- ចុចប៊ូតុងរហូតដល់លេខបញ្ជាក់ពីបរិមាណសំណើមរបស់គ្រាប់ស្រូវបង្ហាញចេញមក
- ត្រូវធ្វើតេស្តយ៉ាងតិច៣សំណាក ហើយគណនារកកម្រិតមធ្យមនៃសំណើម
- ត្រូវកែតម្រូវម៉ាស៊ីនឡើងវិញក្នុងករណីកម្រិតគុណភាពគ្រាប់ពូជពុំទាន់ត្រូវស្តង់ដារ។

### ៣.១២.៥. ការវេចខ្ចប់

ជាទូទៅ ក្នុងដំណើរការសម្អាតគ្រាប់ពូជដោយម៉ាស៊ីនទំនើប ការងារច្រកវេចខ្ចប់ត្រូវដំណើរការស្របជាមួយគ្នាតែម្តង។ ការវេចខ្ចប់ត្រូវអនុវត្តតាមចំណុចមួយចំនួនដូចខាងក្រោម៖

- ត្រូវវេចខ្ចប់គ្រាប់ពូជស្រូវក្នុងចំណុះបាវតម្រូវទៅតាមបរិមាណដែលអ្នកទិញចង់បាន ដូចជា៖ ចំណុះ ១០ គ.ក្រ ឬ ២០ គ.ក្រ ឬ ២៥ គ.ក្រ ជាដើម
- ត្រូវមានស្លាកគ្រាប់ពូជ(Seed labal) លើសម្បកវេចខ្ចប់ដែលបង្ហាញនូវលក្ខណៈសម្គាល់របស់គ្រាប់ពូជស្រូវ និងលេខទូរស័ព្ទទំនាក់ទំនងរបស់ស្ថាប័ន (កសិដ្ឋាន ស្ថានីយ៍កសិកម្ម ឬសហគមន៍ ផលិតគ្រាប់ពូជស្រូវ) ដើម្បីឱ្យអ្នកទិញអាចទាក់ទងទៅកាន់អ្នកផលិតគ្រាប់ពូជស្រូវសម្រាប់ទិញគ្រាប់ពូជ ឬទទួលបានការណែនាំផ្នែកបច្ចេកទេសឬបណ្តឹងសារទុក្ខក្នុងករណីបើមាន។
- ត្រូវមានព័ត៌មានលើស្លាកគ្រាប់ពូជ ដូចជា៖ឡូហ្គូអង្គភាព ឬក្រុមហ៊ុនឬសមាគម ឈ្មោះពូជចំណាត់ថ្នាក់ពូជ លេខឡូតិ៍ កាលបរិច្ឆេទផលិត ទម្ងន់គ្រាប់ពូជ១

កញ្ចាប់ និងស្តង់ដារគ្រាប់ពូជ

- ត្រូវជ្រើសរើសពណ៌សម្បកបាវ និងការដេរឱ្យមានពណ៌ខុសៗគ្នាចំពោះចំណាត់ថ្នាក់ខុសៗគ្នា

- ត្រូវយកសំណាកនៅពេលវេចខ្ចប់សំណាក់គ្រាប់ពូជនៃឡូតិ៍នីមួយៗតម្កល់ទុក ៣-៥ គ.ក្រ រហូតដល់ផុតរដូវដាំដុះដើម្បីទុកធ្វើជាភ័ស្តុតាងករណីមានការប្តឹងត៉វ៉ាពីអ្នកទិញ

- ត្រូវមានរបាយការណ៍កែច្នៃគ្រាប់ពូជដែលមានការកត់ត្រាលម្អិតតាមប្រភេទពូជ ចំណាត់ថ្នាក់លេខឡូតិ៍ បរិមាណពូជឆៅ បរិមាណគ្រាប់ពូជសម្អាតរួច និងកាកសំណល់។

### ៣.១២.៦. ការស្តុកគ្រាប់ពូជស្រូវ

គុណភាពគ្រាប់ពូជមានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងទិន្នផលដំណាំ។ ដូច្នេះគ្រាប់ពូជទាំងអស់ ត្រូវមានលក្ខខណ្ឌនៃការថែរក្សាទុកដាក់ ឱ្យបានប្រសើរបំផុតដែលត្រូវអនុវត្តឱ្យបានតាមលក្ខណៈបច្ចេកទេស ដើម្បីរក្សាបាននូវគុណភាពគ្រាប់ពូជសមស្របតាមស្តង់ដារ។ ដើម្បីធានាគុណភាពគ្រាប់ពូជស្រូវក្នុងអំឡុងពេលរក្សាទុកនៅក្នុងឃ្លាំង ត្រូវអនុវត្តតាមចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- មិនត្រូវទុកដាក់គ្រាប់ពូជក្នុងស្ថានភាពទីតាំងមិនសមស្រប ខុសបច្ចេកទេសធ្វើឱ្យមានការប្រែប្រួលសំណើមគ្រាប់ពូជស្រូវលើសពី១% នោះឡើយ ពីព្រោះវាធ្វើឱ្យប៉ះពាល់ដល់គុណភាពគ្រាប់ពូជស្រូវ

- ត្រូវតែសាងសង់ឃ្លាំងតាមលក្ខណៈបច្ចេកទេសដាក់គ្រាប់ពូជស្រូវ ក្នុងនោះត្រូវយកចិត្តទុកដាក់លើទិសនៃឃ្លាំង កម្ពស់ ខ្យល់អាចចេញចូលបាន ការលេចជ្រាបទឹក សុវត្ថិភាពពីគ្រោះធម្មជាតិ ដូចជា៖ ទឹកជំនន់ និងខ្យល់ព្យុះជាដើម

- ត្រូវអនាម័យឃ្លាំង ធ្វើយ៉ាងណាឱ្យឃ្លាំងស្អាត ស្ងួត និងមិនមានសត្វល្អិតចង្រៃ

- ត្រូវរៀបបាវគ្រាប់ពូជស្រូវដាក់ត្រឹមត្រូវនៅលើក្តារទម្រ(ប៉ាឡែត)។ ក្តារ

ទម្រត្រូវរៀបជាជួរដោយមានជួរមេ និងជួររង។ ជួរមេត្រូវមានចន្លោះ ១,៥ ម និងជួររងមានចន្លោះ ០.៨-១,០ ម ។ ការរៀបចំបែបនេះដើម្បីឱ្យខ្យល់អាចចេញចូលបាន និងងាយស្រួលក្នុងការងារចុះត្រួតពិនិត្យគុណភាពគ្រាប់ពូជនៅក្នុងឃ្លាំងជាប្រចាំ និងងាយស្រួលក្នុងការលើកដាក់បញ្ចេញ ឬបញ្ចូលគ្រាប់ពូជ។

ក្តារទម្រអាចមានទំហំសមស្របគឺបណ្តោយ ១២០ ស.ម ទទឹង១២០ ស.ម និងកម្ពស់ ១៥ ស.ម ដែលអាចដាក់បាវគ្រាប់ពូជស្រូវចំណុះ ២៥ គ.ក្រ បានប្រមាណ ៩០ បាវ និងមានទម្ងន់សរុបប្រមាណ ២.២៥០ គ.ក្រ




រូបភាពទី១៥៖ គំនូរតាង និងរបៀបដាក់ក្តារទម្រគ្រាប់ពូជស្រូវ

ត្រូវមានប័ណ្ណសម្គាល់គំនរព្យួរនៅតាមគំនរគ្រាប់ពូជស្រូវនីមួយៗ ដោយមានការធ្វើបច្ចុប្បន្នភាពនៃបរិមាណគ្រាប់ពូជស្រូវជារៀងរាល់ខែ។

ត្រូវគ្របគំនរគ្រាប់ពូជស្រូវដែលដាក់លើក្តាទម្រ ដោយប្រើសន្លឹកប្លាស្ទិកពណ៌សស្តើង ហើយសង្កត់ជើងប្លាស្ទិកនោះដោយប្រើកូនបាវខ្សាច់ដើម្បីការពារការបំផ្លាញនៃសត្វល្អិតចង្រៃ កណ្តុរ និងពួកសត្វស្លាប់

## សម្គាល់

ការបញ្ចេញស្តុកប្រភេទពូជដូចគ្នាត្រូវអនុវត្តគោលការណ៍ចូលមុនចេញមុន ( First in First out –FIFO )។





*រូបភាពទី១៦៖ របៀបរៀបបាវគ្រាប់ពូជស្រូវលើក្តារទម្រ*

### ៣.១២.៧. ការត្រួតពិនិត្យគុណភាពគ្រាប់ពូជស្រូវ

- **ការត្រួតពិនិត្យសំណើមគ្រាប់ពូជស្រូវ៖** គួរធ្វើតេស្តត្រួតពិនិត្យប្រចាំខែដោយជ្រើសរើសសំណាកតាមវិធីសាស្ត្រចែជន្យពីគំនរគ្រាប់ពូជ ហើយប្រើប្រាស់ឧបករណ៍វាស់សំណើមដើម្បីវាស់កម្រិតសំណើមរបស់គ្រាប់ពូជស្រូវ។ ប្រសិនបើសំណើមរបស់គ្រាប់ពូជស្រូវខ្ពស់ជាងកម្រិតស្តង់ដារដូច្នេះ គួរសម្ងួតគ្រាប់ពូជឡើងវិញរហូតដល់កម្រិតសំណើមធ្លាក់ចុះមកត្រឹមកម្រិតស្តង់ដារទៅតាមចំណាត់ថ្នាក់គ្រាប់ពូជនីមួយៗ។ ការសម្ងួតឡើងវិញនេះត្រូវចំណាយថវិកាច្រើន និងធ្វើឱ្យប៉ះពាល់ដល់គុណភាពគ្រាប់ពូជ។ ដូច្នេះ ចៀសវាងករណីនេះ ត្រូវប្រុងប្រយ័ត្នពេលសម្ងួតឱ្យដល់កម្រិតស្តង់ដារ និងពិនិត្យមើលឃ្លាំងចំពោះការលេចជ្រាបទឹក ជាពិសេសពេលរដូវត្រជាក់ រដូវភ្លៀងដែលសំណើមបរិយាកាសមានកម្រិតខ្ពស់ត្រូវការពារយ៉ាងណាកុំឱ្យផ្ទៃខាងក្នុងឃ្លាំងមានការប្រែប្រួលតាមបរិយាកាសខាងក្រៅខ្លាំងពេក។

- **ការត្រួតពិនិត្យដំណុះគ្រាប់៖** ធ្វើតេស្តត្រួតពិនិត្យឱ្យបានទៀតទាត់ និងជារៀងរាល់ខែលើកម្រិតដំណុះគ្រាប់ ជាពិសេសមួយសប្តាហ៍មុនពេលប្រគល់ទៅឱ្យអ្នកទិញ។ ការធ្វើតេស្តពិនិត្យប្រចាំខែគួរត្រូវបានធ្វើឡើងតាមរយៈការប្រមូលសំណាកដោយ

ចៃដន្យពីស្តុកគ្រាប់ពូជស្រូវ ហើយធ្វើតេស្តពិនិត្យកម្រិតដំណុះគ្រាប់ចំនួន៣សារដើម្បីផ្ទៀងផ្ទាត់មើលកម្រិតដំណុះគ្រាប់។ ប្រសិនបើលទ្ធផលបង្ហាញថា មានការធ្លាក់ចុះភាគរយនៃដំណុះគ្រាប់ទាបជាងកម្រិតស្តង់ដារ ដូច្នេះត្រូវស្វែងរកមូលហេតុនៅពីក្រោយនៃការធ្លាក់ចុះនេះ។ ករណីគ្រាប់ពូជថ្មី ឬពុំទាន់អស់សុពលភាពដំណុះ(តិចជាង៦ខែក្រោយពេលប្រមូលផល) ត្រូវធ្វើតេស្តសារជាថ្មី។ តែករណីធ្លាក់ចុះដោយសារអស់សុពលភាពនៃដំណុះ ត្រូវធ្វើសេចក្តីរាយការណ៍ជូនអ្នកគ្រប់គ្រងដើម្បីផ្អាកការបញ្ចេញលក់ជាគ្រាប់ពូជ។



*រូបភាពទី១៧៖ ការត្រួតពិនិត្យដំណុះគ្រាប់ពូជស្រូវប្រចាំខែ*

**កាត្រួតពិនិត្យសត្វល្អិត និងសត្វចង្រៃ៖** កម្រិតបំផ្លាញរបស់សត្វល្អិតចង្រៃអាស្រ័យលើការថែទាំចំពោះគ្រាប់ពូជស្រូវដែលបានរក្សាទុក។ ត្រូវពិនិត្យគំនរគ្រាប់ពូជជារៀងរាល់សប្តាហ៍ដើម្បីស្វែងរកថាតើមានសញ្ញាណនៃការវាយប្រហារពីសត្វល្អិត និងសត្វចង្រៃឬទេ។ ដើម្បីទប់ស្កាត់ការខូចខាតដោយសារតែសត្វល្អិត និងសត្វចង្រៃ ត្រូវសម្អាតឃ្លាំងឱ្យបានត្រឹមត្រូវ ហើយក្នុងករណីមានការវាយប្រហារបែបនេះ ត្រូវចាត់

វិធានការភ្លាមៗ។ ត្រូវដាក់ថ្នាំបំពុលក្នុងករណីមានការបំផ្លាញពីសត្វល្អិត ដូចជា ខ្មូត ដោយអនុវត្តធូបទកម្ម( Fumigation )។

### ៣.១២.៨. ស្លាកសម្គាល់គ្រាប់ពូជស្រូវ( ស្លាកសញ្ញាព័ត៌មាន )

#### ក. ផ្នែកខាងមុខ( ផ្នែកសំខាន់នៃសម្បកវេចខ្ចប់ )

ចេញវិញ្ញាបនប័ត្រដោយ:........................................... លេខ..............
ពូជដំណាំ:...............................................................
ឈ្មោះពូជ:..............................................................
ចំណាត់ថ្នាក់គ្រាប់ពូជ:.............................................
ពាណិជ្ជសញ្ញា:........................................................
លេខវិញ្ញាបនបត្របញ្ជាក់គុណភាព:..............................
អត្រាសំណើម(%):....................................................
អត្រាដំណុះ(%):......................................................
ភាពសុទ្ធនៃគ្រាប់ពូជ(%):..........................................
កាលបរិច្ឆេទផលិតផល និងវេចខ្ចប់:..............................
កាលបរិច្ឆេទផុតសុពលភាព:......................................
ប្រភេទថ្នាំកសិកម្មដែលប្រើសម្រាប់ការពារ:......................
របៀបប្រើប្រាស់:.......................................................

#### ខ. ផ្នែកខាងខ្នង (ផ្នែកបន្ទាប់បន្សំ) នៃសម្បកវេចខ្ចប់

ឈ្មោះ អាសយដ្ឋានស្ថាប័ន ក្រុមហ៊ុន ឬប្រទេស ប្រភពដើមផលិត កែច្នៃគ្រាប់ពូជ:
.........................................................................................
ឈ្មោះ ឡូហ្គោ អាសយដ្ឋានស្ថាប័ន ឬក្រុមហ៊ុន ឬប្រទេសនាំចូលនិងចរាចរលើទីផ្សារ:
.........................................................................................
លេខឡូតិ៍:..............................................................................
បរិមាណគ្រាប់ពូជ:....................................................................

### ៣.១២.៩. អ្នកផលិតគ្រាប់ពូជស្រូវ

ដើម្បីឆ្លើយតបទៅនឹងលទ្ធភាពទទួលបានគ្រាប់ពូជស្រូវ ដែលមានគុណភាពខ្ពស់សម្រាប់កសិករ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកពាក់ព័ន្ធផ្សេងទៀតការពង្រីកឱ្យមានផលិតកម្មផលិតគ្រាប់ពូជឈានដល់កម្រិតគ្រាប់ពូជវិញ្ញាបនបត្រ( គ្រាប់ពូជគ្រឹះ គ្រាប់ពូជចុះបញ្ជីគ្រាប់ពូជវិញ្ញាបនបត្រ ) ដើម្បីធានាឱ្យបាននូវគុណភាពគ្រាប់ពូជស្រូវល្អ។

ការពង្រឹងសមត្ថភាពដល់ភាគីពាក់ព័ន្ធ ក្នុងខ្សែច្រវ៉ាក់ផលិតកម្ម និងបណ្ដាញផ្គត់ផ្គង់គ្រាប់ពូជដែលមានគុណភាពខ្ពស់ ដោយបំពាក់បំប៉នពួកគេក៏ដូចជាការអភិវឌ្ឍចំណងទាក់ទង ក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ និងប្រគល់ការទទួកខុសត្រូវដល់ពួកគេក្នុងការផលិត និងផ្គត់ផ្គង់នូវគ្រាប់ពូជស្រូវដែលមានគុណភាពតាមស្តង់ដារប្រកបដោយនិរន្តរភាព។ ធ្វើបែបនេះនឹងជួយបង្កើនផលិតភាពស្រូវ ការធ្វើពាណិជ្ជកម្ម និងបន្ថែមគុណតម្លៃដល់ផលិតកម្មស្រូវនៅគ្រប់តំបន់។

### ៣.១២.១០. កម្មវិធីផលិតគ្រាប់ពូជគ្រឹះ

នាពេលបច្ចុប្បន្ន វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកសិកម្មកម្ពុជា (CARDI) គឺជាប្រភពតែមួយគត់ ដែលមានការទទួលស្គាល់ មានកេរ្តិ៍ឈ្មោះ និងអាចជឿជាក់បានសម្រាប់ផលិតគ្រាប់ពូជគ្រឹះនៅកម្ពុជា។ ខណៈដែល វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា (CARDI) មានសមត្ថភាពពេញលេញក្នុងការផលិតគ្រាប់ពូជគ្រឹះ។

ដើម្បីអនុវត្តរាល់សកម្មភាពផលិតកម្មទាំងអស់ឱ្យបានទាន់ពេលវេលា អង្គភាពពាក់ព័ន្ធមានដូចជា មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ កសិដ្ឋាន និងស្ថានីយកសិកម្ម ត្រូវត្រៀមរៀបចំផែនការផលិតកម្មឱ្យរួចរាល់មួយឆ្នាំមុន ដើម្បីឱ្យខ្លួនអាចចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្រាប់ការផលិតនៅឆ្នាំបន្ទាប់ជាមួយនឹងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា (CARDI) ក្រុមហ៊ុនផលិតពូជស្រូវ ឬក្រុមហ៊ុនឯកជនសមស្របនានា។ បរិមាណគ្រាប់ពូជគ្រឹះដែល

ត្រូវការជាក់លាក់ត្រូវបញ្ជាក់ឱ្យបានច្បាស់នៅក្នុងការបញ្ជាទិញ ហើយបញ្ជូនទៅឱ្យវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍកសិកម្មកម្ពុជា (CARDI) ឬអ្នកផលិតដទៃទៀតដែលមានការទទួលស្គាល់ដោយរដ្ឋ។

### ៣.១២.១១. កម្មវិធីផលិតគ្រាប់ពូជចុះបញ្ជី

ដើម្បីមានលទ្ធភាពផ្គត់ផ្គង់បានគ្រប់គ្រាន់នូវគ្រាប់ពូជស្រូវចំណាត់ថ្នាក់ចុះបញ្ជីនៅក្នុងតំបន់ផលិតស្រូវរបស់ប្រទេសកម្ពុជា ដៃគូពាក់ព័ន្ធដែលមានភារៈកិច្ចផលិតពូជស្រូវ ត្រូវរៀបចំផែនការទិញគ្រាប់ពូជស្រូវចំណាត់ថ្នាក់ពូជគ្រឹះដើម្បីផលិតឱ្យចេញទៅជាចំណាត់ថ្នាក់ពូជចុះបញ្ជីដែលមានគុណភាពស្របតាមស្តង់ដារត្រឹមត្រូវ។ ទន្ទឹមនេះអង្គភាពផលិតគ្រាប់ពូជពិសេសស្ថានីយ៍កសិកម្ម ក៏ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍កសិកម្ម ក្រុមកសិករផលិតគ្រាប់ពូជស្រូវក្នុងខ្សែច្រវាក់ផលិតកម្ម និងខ្សែច្រវាក់ផ្គត់ផ្គង់សម្រាប់ចែកចាយឱ្យបានគ្រប់គ្រាន់នូវគ្រាប់ពូជវិញ្ញាបនបត្រដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នកផលិតស្រូវនៅក្នុងប្រទេសកម្ពុជា។

### ៣.១២.១២. កម្មវិធីផលិតគ្រាប់ពូជវិញ្ញាបនបត្រ

ការផ្គត់ផ្គង់គ្រាប់ពូជស្រូវ វិញ្ញាបនបត្រដល់កសិករ ក្រុមកសិករ សហគមន៍កសិកម្ម វិស័យឯកជន និងភាគីពាក់ព័ន្ធដទៃ នៅតាមបណ្តារាជធានី-ខេត្ត ឱ្យមាននិរន្តរភាពគឺជាការចាំបាច់ដើម្បីលើកកម្ពស់លទ្ធភាពអាចរកបាននូវគ្រាប់ពូជស្រូវមានគុណភាពស្តង់ដារ ដែលជួយបង្កើនគុណភាពស្រូវអង្ករ និងជំរុញការចូលរួមរបស់កម្ពុជាចូលរួមទៅក្នុងទីផ្សារនាំចេញ។

ដើម្បីសម្រេចបានគោលដៅខាងលើនេះ អង្គភាពដែលមានភារៈកិច្ចផ្គត់ផ្គង់គ្រាប់ពូជស្រូវ វិញ្ញាបនបត្រ ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងសហគមន៍កសិកម្ម និងក្រុមកសិករផលិតគ្រាប់ពូជស្រូវ ដើម្បីធានាដល់ការផ្គត់ផ្គង់ស្របតាមតម្រូវការពីសំណាក់កសិករ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ និងអ្នកទិញពូជផ្សេងៗទៀតនៅតាមបណ្តារាជធានី-ខេត្ត។

សហគមន៍កសិកម្ម និងក្រុមកសិករផលិតគ្រាប់ពូជ ត្រូវត្រៀមរៀបចំផែនការ ផលិតគ្រាប់ពូជវិញ្ញាបនបត្រមួយឆ្នាំមុន ដោយធ្វើការវាយតម្លៃផ្អែកទីផ្សារ និងការបញ្ជាទិញគ្រាប់ពូជស្រូវដែលទទួលបានពីអ្នកទិញ។ សហគមន៍កសិកម្ម និងក្រុមកសិករផលិតគ្រាប់ពូជស្រូវ ត្រូវរៀបចំផែនការផលិតគ្រាប់ពូជស្រូវឱ្យបានចប់សព្វគ្រប់ដោយផ្អែកលើការវាយតម្លៃ ការបញ្ជាទិញ ទាំងបិមាណ និងគុណភាពរបស់អ្នកទិញ។ ដើម្បីអនុវត្តរាល់សកម្មភាពផលិតកម្មពូជទាំងអស់ឱ្យបានទាន់ពេលវេលា សហគមន៍កសិកម្ម និងក្រុមកសិករផលិតគ្រាប់ពូជត្រូវបញ្ជាទិញគ្រាប់ពូជចុះបញ្ជីពីអង្គភាពផលិតគ្រាប់ពូជរបស់រដ្ឋ និងវិស័យឯកជនដែលបានទទួលដោយរដ្ឋ សម្រាប់ការផលិតនាឆ្នាំបន្ទាប់។

### ៣.១២.១៣. សាលារៀនស្រែកសិករសម្រាប់លើកកម្ពស់ផលិតកម្មគ្រាប់ពូជ

សាលារៀនស្រែកសិករ គឺជាឧបករណ៍សំខាន់ និងជាវិធីសាស្ត្រ ដែលមានប្រសិទ្ធភាពក្នុងការពង្រឹងសមត្ថភាពរបស់កសិករ សមាជិករបស់សហគមន៍កសិកម្ម និងក្រុមកសិករផលិតគ្រាប់ពូជដែលបានចូលរួមនៅក្នុងការផលិតគ្រាប់ពូជ ជាពិសេសផលិតកម្មគ្រាប់ពូជស្រូវ។ ខុសពីវិធីសាស្ត្របណ្តុះបណ្តាលនៅក្នុងថ្នាក់រៀនទូទៅធម្មតា សាលារៀនស្រែកសិករ គឺត្រូវបានអនុវត្តដើម្បីធ្វើបង្ហាញដល់កសិករឱ្យឃើញនូវការអនុវត្តជាំជុះជាក់ស្តែងនៅក្នុងស្រែផលិតកម្មគ្រាប់ពូជស្រូវ ដោយចាប់ផ្តើមពីការរៀបចំរហូតដល់ការច្រូតកាត់ នៅក្នុងទីកន្លែងធ្វើបង្ហាញ។ សាលារៀនស្រែកសិករមិនត្រឹមតែផ្តោតលើការផលិតនៅទីវាលប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ផ្តោតលើប្រតិបត្តិការក្រោយប្រមូលផលដែរ រួមមាន៖ ការសម្ងួត ការសម្អាត ការវេចខ្ចប់ និងការស្តុកទុកគ្រាប់ពូជស្រូវឱ្យបានត្រឹមត្រូវ និងរៀបចំទិវាស្រែសម្រាប់ការផលិតគ្រាប់ពូជស្រូវ។ ការធ្វើដូចនេះនឹងជួយក្នុងការកសាងសមត្ថភាពរបស់កសិករសមាជិកសហគមន៍កសិកម្ម និងក្រុមកសិករផលិតគ្រាប់ពូជក្នុងការងារផលិតកម្ម និងស្តុកគ្រាប់ពូជស្រូវវិញ្ញាបនបត្រ៕

# ឯកសារយោង៖


១. សៀវភៅណែនាំស្តីពីផលិតកម្មគ្រាប់ពូជ (Rice Production Manual ),កម្មវិធីជំរុញផលិតកម្មស្រូវ និងនាំអង្ករចេញ Climate-Resilient Rice Commercialization Sector Development Program (Rice-SDP), កក្កដា ២០១៨

២. វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ២០១០, ការគ្រប់គ្រងជីជាតិដីលើដំណាំស្រូវនៅកម្ពុជា

៣. វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ២០០៧, ដំណាំស្រូវនៅកម្ពុជា

៤. កម្មវិធី IPM 2006, គោលការណ៍ណែនាំ អនុវត្តនៅវាលស្រែសម្រាប់សាលារៀនស្រែកសិករលើដំណាំស្រូវ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៥. CEDAC, 2005, ប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ,កម្ពុជា

៦. កម្មវិធី IPM, 1998, សត្វសំខាន់ក្នុងប្រព័ន្ធបរិស្ថានដំណាំស្រូវ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៧. នាយកដ្ឋានក្សេត្រសាស្ត្រ និងអង្គការស៊ីដសេ ១៩៩៧, ផលិតកម្មដំណាំស្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៨. ងិន ឆាយ ១៩៩៧, កិច្ចការពារដំណាំ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

៩. បណ្ឌិត ភីធើរ វ៉ាយ, លោក តូម៉ាស់ អូបឺតួរ និងលោក ភាវ សុវុទ្ធី, ១៩១៧ ដីប្រើប្រាស់សម្រាប់ផលិតកម្មដំណាំស្រូវនៅកម្ពុជា, វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា។







**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : ០១៧ ៩៥៩ ៧២៧/០៨៥ ២២ ៤៨ ៤៨

**គេហទំព័រ** : www.deaff.maff.gov.kh / khmeragri.info